ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

១៩-១០-២០០៧ -ព្រះរាជក្រម នស/រកម/១០០៧/០២៩ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ៣ ទី ៥ ទី ១០ និងពិធីសារទី ២ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ៨៦២៥

២-ព្រះរាជក្រឹត្យ

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០៧ ស្តីពីការតែងតាំងឯកឧត្តម **មាស សារុន** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៨៧២១

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០៨ ស្តីពីការតែងតាំងមន្ត្រីថ្នាក់ដឹកនាំ នៃរាជបណ្ឌិតសភាកម្ពុជា ចំនួន ០៥ រូប ៨៧២២

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០៩ ស្តីពីការតែងតាំងលោក Alain Benicy ជាទីប្រឹក្សារាជរដ្ឋាភិបាល ទទួលការងារកំណែទម្រង់រដ្ឋបាល ៨៧២៤

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥១០ ស្តីពីការតែងតាំងលោកជំទាវ **អ៊ុំ ស៊ុំស្រួន** ជាឧកញ៉ា ៨៧២៥

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥១១ ស្តីពីការតែងតាំងលោកស្រី **គាត ហោរ៉ុត** ជាឧកញ៉ា ៨៧២៦

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥១២ ស្តីពីការតែងតាំងលោកស្រី **យិន ផាន្នី** ជាឧកញ៉ា ៨៧២៧

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥១៥ ស្តីពីការតម្លើងឋានន្តរស័ក្តិជូននាយ នគរបាលជាតិជាន់ខ្ពស់ ចំនួន ០៣ នាក់ នៃក្រសួងមហាផ្ទៃ ៨៧២៨

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

២២-១០-២០០៧-អនុក្រឹត្យលេខ ១៥៤ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ៨៧២៩
២២-១០-២០០៧-អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ស្តីពីការឈប់ទទួលស្គាល់សាកលវិទ្យាល័យវ៉ែនឡែន ៨៧៣១
២៤-១០-២០០៧-អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ស្តីពីការផ្ទេរគណទានថវិកា ៨៧៣៣
១៥-១០-២០០៧-អនុក្រឹត្យលេខ ៨៣៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៣៥
១៥-១០-២០០៧-អនុក្រឹត្យលេខ ៨៣៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៣៦
១៥-១០-២០០៧-អនុក្រឹត្យលេខ ៨៣៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៧៣៨

ព្រះរាជក្រម

នស/រកម/១០០៧/០២៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី៣ ទី៥ ទី១០ និងពិធីសារទី២ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាព-មីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្ដីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញពេញអង្គព្រឹទ្ធសភា ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ៣ ទី ៥ ទី ១០ និងពិធីសារទី ២ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

មាត្រា ១.–

អនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ៣ ទី ៥ ទី ១០ និងពិធីសារទី ២ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលធ្វើនៅទីក្រុងគុនមីង ខេត្តយូណាន់ សាធារណរដ្ឋប្រជាមា-

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

នគបន នាថ្ងៃទ ៥ ខែ កក្កដា ឆ្នាំ ២០០៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តឧបសម្ព័ន្ធ និងពិធីសារនៃកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.០៧១០.៥៤៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា

ស៊ុន ចាន់ថុល

[illegible]: ៥០០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ឌិនគេង

ឧបសម្ព័ន្ធទី ៣

ការដឹកជញ្ជូនទំនិញខាយខូចគុណភាព

ANNEX 3

CARRIAGE OF PERISHABLE GOODS

ឧបសម្ព័ន្ធទី ៣

ការដឹកជញ្ជូនទំនិញខាងខូចគុណភាព

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីអំពីការសំរបសំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាត់ថា ឧបសម្ព័ន្ធ)

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម(តទៅហៅកាត់ថា "ភាគីចុះកិច្ចសន្យា") ។

យោង កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ នៅទីក្រុងវៀងច័ន្ទ និងធ្វើវិសោធនកម្ម នាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងយ៉ាងហ្គូន ដែលបានយល់ព្រមចូលដោយព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងយ៉ាំងហ្គូន នាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋ ប្រជាមានិតចិន នាថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូលដោយសហភាពមីយ៉ាន់ម៉ា នាថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា " កិច្ចព្រមព្រៀង " ។

យោង មាត្រាទី ៣(បេ) និង(អិន)នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេសទៅតាមទីកន្លែងហើយ ដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា ។

យោង មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ។

យោង កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានីលឡា ក្នុងខែមករា ឆ្នាំ២000 កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ២០០២ និងកិច្ចប្រជុំលើកទី១១រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្កើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសាររបស់វាក្នុងឆ្នាំ ២០០៥ ។

យោង មាត្រា ៣(អឹម) និង១០(បេ)នៃកិច្ចព្រមព្រៀងដែលបានស្នើឱ្យឧបសម្ព័ន្ធនេះ ចែងលំអិតអំពីផ្នែកបច្ចេកទេស ។

បានព្រមព្រៀងគ្នាដូចខាងក្រោម :

ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.- និយមន័យ

សំរាប់គោលបំណងនៃឧបសម្ព័ន្ធនេះ ពាក្យ "**ទំនិញងាយខូចគុណភាព**" មានន័យថា សារធាតុសរីរាង្គទាំងឡាយ ឬ សរីរាង្គមានជីវិតទាំងឡាយ ដែលងាយទទួលរងនូវការខូចរលួយ ដែលមិនអាចយកទៅលក់ដូរបាននៅទីផ្សារ ឬស្លាប់នៅក្រោមឥទ្ធិពលរួមគ្នានៃថេរវេលា និងស្ថានភាពនៃការដឹកជញ្ជូន ដូចជាសីតុណ្ហភាព (ក្តៅ ឬត្រជាក់) សំណើម ឬសម្ពាធ ឬចលនាចរាចរ ។

មាត្រា ២.- ប្រព័ន្ធអាទិភាព

ក- ទំនិញងាយខូចគុណភាព ដែលមានរាយក្នុងបញ្ជីនៃសេចក្តីភ្ជាប់ ត្រូវបានគេផ្តល់ឱ្យសំរាប់ជាប្រព័ន្ធអាទិភាពមួយក្នុងការជំរះបែបបទឆ្លងកាត់ព្រំដែន ដោយអនុលោមទៅតាមលំដាប់លំដោយអាទិភាព ដែលបានកំណត់នៅក្នុងមាត្រា៩ នៃឧបសម្ព័ន្ធទី៤ នៃកិច្ចព្រមព្រៀង ។ បញ្ជីនេះអាចកែសំរួលឡើងវិញបាន ពីមួយពេលទៅមួយពេលទៀត ដោយមានការព្រមព្រៀងគ្នាពីភាគីចុះកិច្ចសន្យា តាមរយៈគណៈកម្មការរួម ។

ខ- សំរាប់ជាគោលបំណងក្នុងការសំរួលការដឹកជញ្ជូន ភាគីចុះកិច្ចសន្យា ត្រូវជូនដំណឹងគ្នាទៅវិញទៅមក នូវបញ្ជីទំនិញងាយខូចគុណភាពរបស់ខ្លួនរៀង១ខ្លួន សំរាប់ការជំរះបែបបទខាងចត្តាឡីស័ក (quarantine) ដែលអាចធ្វើឡើង និងការផ្លាស់ប្តូរទាំងឡាយដែលមាន តាមរយៈមន្ត្រីទំនាក់ទំនងដែលកំណត់នៅក្នុងមាត្រា៤(ឃ) នៃឧបសម្ព័ន្ធនេះ ។

មាត្រា ៣.- តំរូវការ និងឯកសារខាងសុខភាព អនាម័យ និងភូតគាមនាម័យ

ទំនិញងាយខូចគុណភាពទាំងឡាយ ត្រូវបានគេអនុញ្ញាតអោយដឹកជញ្ជូនឆ្លងកាត់ព្រំដែន លុះត្រាតែវាស្របទៅនឹងបទប្បញ្ញត្តិជាតិខាងសុខភាព អនាម័យ និង/ឬ ភូតគាមនាម័យទាំងឡាយ និងត្រូវអមជាមួយនូវវិញ្ញាបនប័ត្រ /ឯកសារខាងសុខភាព អនាម័យ និង/ឬភូតគាមនាម័យផងដែរ ។ ផ្នែកដែលពាក់ព័ន្ធទាំងឡាយ នៃតំរូវការទាំងពីរខាងលើនេះ ត្រូវអនុលោមទៅតាមមាត្រាទី៩ នៃកិច្ចព្រមព្រៀង ។

មាត្រា ៤.- យន្តការខាងស្ថាប័ន

ក- ភាគីចុះកិច្ចសន្យា ត្រូវសំរបសំរួលសកម្មភាពទាំងឡាយរបស់គេ ក្នុងការអនុវត្តឧបសម្ព័ន្ធនេះ និងដោះស្រាយរាល់បញ្ហាទាំងឡាយដែលកើតឡើងពីករណីទាំងនេះ តាមរយៈអនុគណៈកម្មការខាងសុខភាពអនាម័យ និង

/ឬ ភូតតាមនាម័យនៃគណៈកម្មការរួម ដែលបានបង្កើតឡើងកាលពីថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៤ នៅទីក្រុង ភ្នំពេញ និងយន្តការដូចគ្នានេះផ្សេងៗទៀត រវាង និងក្នុងរង្វង់ពួកគេដែលជាភាគីចុះកិច្ចសន្យា ។

ខ- ភាគីចុះកិច្ចសន្យា ត្រូវជូនដំណឹងគ្នាទៅវិញទៅមក នូវអាស័យដ្ឋានទំនាក់ទំនង សំរាប់ការអនុវត្តឧបសម្ព័ន្ធនេះ និងការផ្លាស់ប្តូរទាំងឡាយដែលមានជាបន្តបន្ទាប់ ។

មាត្រា ៥.- បទដ្ឋាន (ស្តង់ដារ) សំរាប់ប្រភេទពិសេសនានាឡាយ នៃទំនិញងាយខូចគុណភាព

សំរាប់ប្រភេទពិសេសៗចំនួន០២ នៃទំនិញងាយខូចគុណភាព ឧទាហរណ៍ : (ក)សត្វរស់ និង(ខ)ម្ហូបអាហារងាយខូចគុណភាពសំរាប់មនុស្សបរិភោគ ដើមរុក្ខជាតិរស់ និងជាគ្រឿងតុបតែងលំអ និងផ្កាកាត់ ឧបសម្ព័ន្ធនេះនឹងមានចែងលំអិតបទដ្ឋានដឹកជញ្ជូនថែមទៀត ។

មាត្រា ៦.- សភាពធម្មជាតិជាអនុសិទ្ធ នៃបទដ្ឋាន (ស្តង់ដារ)

ផ្នែកទី២ និងទី៣ នៃឧបសម្ព័ន្ធនេះ បានចែងឡើងដើម្បីទុកជាអនុសាសន៍ ដែលអាចប្រើប្រាស់ជាមគ្គុទេសក៍ ឬជាសេចក្តីណែនាំដល់ភាគីចុះកិច្ចសន្យា ក្នុងបទប្បញ្ញត្តិច្បាប់របស់ពួកគេសំរាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន នៃ(ក)សត្វរស់ និង(ខ) ម្ហូប អាហារងាយខូចគុណភាព សំរាប់មនុស្សបរិភោគ ដើមរុក្ខជាតិរស់ និងជាគ្រឿងតុបតែងលំអ និងផ្កាកាត់ ។

ផ្នែកទី ២
សត្វរស់

មាត្រា ៧.- ទំហំវិសាលភាពនៃការអនុវត្ត

ផ្នែកនេះត្រូវអនុវត្តចំពោះការដឹកជញ្ជូនឆ្លងកាត់ព្រំដែន នៃសត្វមានជីវិត ដោយយានយន្តដឹកជញ្ជូនផ្លូវគោក ។

មាត្រា ៨.- ភាពសមរម្យ

សត្វអាចត្រូវគេដឹកជញ្ជូនបានលុះត្រាតែ វាសមទំនង ឬត្រូវល្មមទៅនឹងដំណើរដឹកជញ្ជូនដែលគេបានត្រៀមបំរុងទុកជាមុន ។ សត្វដែលឈឺ ឬរបួស មិនត្រូវបានពិចារណាថាសមទំនងទៅនឹងការដឹកជញ្ជូនទេ ។ ត្រូវអនុវត្តករណីដូចគ្នានេះសំពោះសត្វទាំងឡាយដែលជិតគ្រប់ខែ ។

មាត្រា ៩.- ការគូសសញ្ញាសំគាល់ លើមធ្យោបាយដឹកជញ្ជូន

យានយន្ត និងកុងតឺន័រដែលដាក់សត្វសំរាប់ដឹកជញ្ជូន ត្រូវដាក់សញ្ញាសំគាល់ដែលមានសញ្ញាបញ្ជាក់អំពីវត្តមាន "សត្វរស់" និងសញ្ញាដែលបញ្ជាក់ពីជំហរឈរត្រង់ឡើងលើរបស់សត្វ ។

មាត្រា ១០.- ជាសុខភាព សុវត្ថិភាព និងអនាម័យ

ក- សត្វមិនត្រូវបានអនុញ្ញាតអោយដឹកជញ្ជូនក្នុងករណីដែលការដឹកជញ្ជូនអាចបង្កអោយមានរបួសស្នាម ឬមានការ ឈឺមានការឈឺចុកចាប់មិនចាំបាច់ណាមួយដល់សត្វទាំងនោះ ។ ការថែរក្សាសត្វគួរត្រូវធ្វើឡើងការពារ

កុំឱ្យសត្វ ស្ថិតនៅក្រោមឥទ្ធិពលនៃការផ្លាស់ប្តូរល្បឿនបើកបរ ឬទិសដៅដឹកជញ្ជូនភ្លាម១ ។

ខ- មធ្យោបាយដឹកជញ្ជូនត្រូវមានលក្ខណៈងាយស្រួលក្នុងការបោសសំអាត មានទ្វារសំរាប់សត្វរំដោះខ្លួនចេញ ដូច្នេះត្រូវតំឡើង និងដាក់អោយប្រើប្រាស់អោយសមល្មម និងធន់នឹងទំងន់សត្វ និងមិនបណ្តាលឱ្យសត្វមានរបួស ឬរងការឈឺចុកចាប់មិនចាំបាច់ ព្រមទាំងធានាសុវត្ថិភាពដល់សត្វទាំងនោះនៅក្នុងពេលដឹកជញ្ជូន ។

គ- សត្វត្រូវបានគេដឹកក្នុងមធ្យោបាយដឹកជញ្ជូន ដែលមានបំពាក់ឧបករណ៍ប្រមូលលាមកសត្វ និងដែលមានការសំអាតយ៉ាងម៉ត់ចត់ និងការរំងាប់មេរោគតាមការសមរម្យ ។

ឃ- សត្វស្លាប់ សំរាមក្រាលអោយសត្វដេក និងលាមកសត្វ ត្រូវប្រមូលយកចេញយ៉ាងឆាប់រហ័សបំផុត និងចាត់ចែងទុកដាក់ឱ្យស្របទៅនឹងបទប្បញ្ញត្តិជាតិពាក់ព័ន្ធទាំងឡាយ ខាងសុខភាព និងអនាម័យ ។

ង- កូនគោនៅបៅដោយមិនបានយកមេទៅតាមជាមួយ កូនគោទាំងនោះត្រូវផ្តល់ទឹកដោះ ឬបំបៅដោះប្រមាណ ១២ម៉ោងម្តង ។

មាត្រា ១១.- តំរូវការទីធ្លា

ត្រូវផ្តល់ទីធ្លា-កន្លែងសមរម្យ នៅលើមធ្យោបាយដឹកជញ្ជូន សំរាប់ឱ្យសត្វអាចស្ថិតនៅក្នុងជំហរធម្មជាតិរបស់វា (ឈរ អង្គុយ ឬដេក ទៅតាមករណីដែលអាចមាន) និងពេលណាចាំបាច់ ត្រូវមានខណ្ឌជាផ្នែក១ សំរាប់ការពារសត្វទាំងនោះពីការ ប៉ះទង្គិចគ្នា ពេលយានយន្តធ្វើចលនា ។ ដង់ស៊ីតេ (ចំណុះ)បន្ទុកត្រូវអនុញ្ញាតឱ្យមានការបញ្ចេញបញ្ចូលខ្យល់ និងលំហខ្យល់គ្រប់គ្រាន់ ។

មាត្រា ១២.- ជំរក និងការបញ្ចេញបញ្ចូលខ្យល់

មធ្យោបាយដឹកជញ្ជូនត្រូវដំឡើងនិងដាក់អោយប្រើប្រាស់ សំរាប់ដឹក និងការពារសត្វពីអាកាសធាតុមិនល្អ មិនសមស្រប ឬខុសពីធម្មតាខ្លាំងក្លាហួសប្រមាណ និងអវិជ្ជមាន និងដាក់សញ្ញាសំគាល់ផ្សេង១គ្នាទៅតាមល័ក្ខខ័ណ្ឌប្រែប្រួល នៃអាកាសធាតុ ។ ក្រៅពីនោះមធ្យោបាយដឹកជញ្ជូនត្រូវមានប្រក់ដំបូល និងមានចំនួនរន្ធខ្យល់គ្រប់គ្រាន់ ឬមធ្យោបាយផ្សេង១ទៀត ដើម្បីធានាអោយមានខ្យល់ចេញ-ចូលគ្រប់គ្រាន់ ។

មាត្រា ១៣.- វិយោគកម្ម ឬការដាក់សត្វអោយនៅដោយឡែកៗពីគ្នា

ក- សត្វដែលតាមលក្ខណៈធម្មជាតិរបស់វា ជាសត្រូវ ឬមានអរិសភាពនឹងគ្នា ដោយសារតែប្រភេទ ក្រុម ពូក អាយុ ភេទ និងពូជកំណើតរបស់វា ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា ។

ខ- សត្វទាំងឡាយ ដែលមានតំរូវការផ្សេងគ្នាខាងអនាម័យ មិនត្រូវដឹកជញ្ជូនក្នុងមធ្យោបាយតែមួយដូចគ្នាទេ ។

គ- សត្វដែលត្រូវគេដឹកជញ្ជូនទាំងឡាយ ត្រូវធ្វើវិយោគកម្ម ឬដាក់ឱ្យនៅដាច់ដោយឡែកពីមនុស្ស ឬក៏ពីពួកសត្វប្រភេទផ្សេងទៀត ។

មាត្រា ១៤.- ការថែទាំ និងព្យាបាល

ក- សត្វដែលត្រូវដឹកជញ្ជូន ត្រូវមានការថែទាំ និងព្យាបាល ឱ្យថ្នាំ អោយបានសមរម្យល្អប្រសើរ ។

ខ- សត្វដែលឈឺ និងរបួសតាមផ្លូវ ត្រូវទទួលការព្យាបាលមុនគេ តាមការចាំបាច់ដែលអាចធ្វើទៅបាន ។ សត្វទាំងនោះ ត្រូវទទួលការព្យាបាលពីបសុពេទ្យយ៉ាងសមស្រប បើសិនជាចាំបាច់មិនអាចជួយបាន ត្រូវពិឃាតជាបន្ទាន់ ដោយអនុលោមទៅតាមបទប្បញ្ញត្តិជាតិខាងសុខភាព/អនាម័យ ។

គ- ការដាក់ថ្នាំសត្វអោយរម្ងាប់អារម្មណ៍ ឬដេកលក់នោះ មិនត្រូវអនុញ្ញាតអោយធ្វើឡើយ វៀរលែងតែមានព្រឹត្តិការណ៍ ឬករណីពិសេសខុសប្លែកពីធម្មតា និងបន្ទាប់មកនៅពេលមានការត្រួតពិនិត្យផ្ទាល់របស់បសុពេទ្យតែប៉ុណ្ណោះ ។

មាត្រា ១៥.- ការរៀបចំសំរាប់ការត្រួតពិនិត្យ

មធ្យោបាយដឹកជញ្ជូន អាចអនុញ្ញាតឱ្យមានការអង្កេត និងការត្រួតពិនិត្យមើលយ៉ាងងាយស្រួលនូវសត្វដែលគេបានផ្ទុក (ឧទាហរណ៍ តាមបង្អួច ឬគំរបបើកចេញ-ចូល) ។

មាត្រា ១៦.- ពេលវេលាដឹកជញ្ជូន

ក- សត្វត្រូវធ្វើការដឹកជញ្ជូនអោយដល់ទិសដៅ ដោយមិនបង្អែរបង្អង់យឺតយ៉ាវឡើយ ។ ភាគីចុះកិច្ចព្រមព្រៀងត្រូវព្យាយាមសម្របសម្រួលការរៀបចំទាំងអស់ ដើម្បីបង្កើនល្បឿនក្នុងការដឹកជញ្ជូនសត្វរស់ ។ ការប្រគល់-ទទួលសត្វរស់ ត្រូវបានទទួលគុណប្រយោជន៍ចេញពីប្រព័ន្ធអាទិភាពទៅតាមលំដាប់លំដោយ នៃការជំរះបែបបទឆ្លងកាត់ព្រំដែន ដែលស្របទៅនឹងមាត្រា ៩ (លំដាប់អាទិភាព ក្នុងការជំរះបែបបទឆ្លងកាត់ព្រំដែន) នៃឧបសម្ព័ន្ធទី៤ (សំរបសំរួល នៃទំរង់បែបបទឆ្លងកាត់ព្រំដែន) នៃកិច្ចព្រមព្រៀង ។

ខ- ក្នុងដំណើរលើសពី ២៤ម៉ោង ត្រូវរកកន្លែងសំរាប់អោយសត្វសំរាក ផ្តល់ចំណីអាហារ និងផ្តល់ទឹកនៅតាមដងផ្លូវធ្វើដំណើរដោយខានពុំបាន និងសំខាន់ជាងនេះទៀត ត្រូវយកសត្វទាំងនោះចេញពីយានយន្ត ដើម្បីផ្តល់ទីជំរក ។ ទីកន្លែង និងរយៈពេលសំរាប់ផ្ទេរសត្វចេញពីយានយន្ត ត្រូវបានកំណត់ឡើង ដោយអនុលោមទៅតាមបទប្បញ្ញត្តិ ជាតិទាំងឡាយ ដែលពាក់ព័ន្ធខាងសុខភាព និងអនាម័យ ។

ផ្នែកទី ៣

ម្ហូបអាហារខាយខូចគុណភាព និងទំនិញខាយខូចគុណភាពផ្សេងទៀត

មាត្រា ១៧.- វិសាលភាពនៃការអនុវត្ត

ផ្នែកនេះត្រូវអនុវត្តចំពោះការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដោយយានយន្តដឹកជញ្ជូនផ្លូវគោក នូវម្ហូបអាហារងាយខូចគុណភាព សំរាប់មនុស្សម្នាបរិភោគ ដើមរុក្ខជាតិរស់ និងសំរាប់ជាគ្រឿងតុបតែងលំអ និងផ្កាកាត់ ។

មាត្រា ១៨.- អនាម័យនៃមធ្យោបាយដឹកជញ្ជូន

ក- នៅផ្ទៃខាងក្នុងនៃមធ្យោបាយដឹកជញ្ជូន ត្រូវតំលើងយ៉ាងណាអោយធន់នឹងច្រេះស៊ី មិនរង្កើវដល់ផលិតផល មិនបណ្តោយអោយងាយខូចគុណភាពដល់ទំនិញដែលត្រូវដឹក និងមិនបំលែងវត្ថុនានាទៅក្នុងផលិតផលទំនិញដែលត្រូវដឹកជញ្ជូនឡើយ ។ ផ្ទៃខាងក្នុងនៃមធ្យោបាយដឹកជញ្ជូននេះ ត្រូវមានសភាពរលោង និងត្រូវផលិតអំពីសំភារៈ មិនជ្រាបទឹក ផ្តល់ភាពងាយស្រួលដល់ការបោសសំអាត និងការបាញ់ថ្នាំសម្លាប់មេរោគ ។

ខ- វៀរលែងតែមានតំរូវការនៃខ្យល់ចេញ-ចូល និងប្រព័ន្ធបង្ហូរទឹក យានយន្តដែលផ្ទុកទំនិញត្រូវមានដំបូលបិទអោយជិតស្អុង និងមិនជ្រាបទឹក ដើម្បីចៀសវាងមិនអោយមានដី ធូលី កំទេចកំទី មេរោគ (ដូចជាមីក្រុប សត្វល្អិត ចង្រៃ ដង្កូវ) ចេញ-ចូលបាន និងដើម្បីការពារផលិតផលនិងបរិស្ថានក្បែរៗនោះ ដែលបណ្តាលមកពីការជះឥទ្ធិពលពីគ្នាទៅវិញទៅមក ការចំលងរោគ និងការថយចុះ ឬខូចដល់គុណភាពទំនិញ ។ តំរូវការរន្ធខ្យល់ចេញ-ចូល និងបណ្តាញបង្ហូរទឹកទាំងឡាយ ក៏ត្រូវតំឡើងអោយមានប្រព័ន្ធបិទបើកអោយជិតផងដែរ ។

គ- មធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់សំរាប់ដឹកម្ហូបអាហារងាយខូចគុណភាព មិនត្រូវអនុញ្ញាតអោយដឹកសត្វរស់ ឬផលិតផលផ្សេងទៀតដែលធ្វើអោយខូច ឬចំលងមេរោគទៅម្ហូបអាហារ លើកលែងតែវាត្រូវបានគេសំអាត សំលាប់មេរោគយ៉ាងហ្មត់ចត់ និងបំបាត់ក្លិនអាក្រក់នៅពេលណាចាំបាច់ បន្ទាប់ពីការផ្ទេរផលិតផល ឬម្ហូបអាហារ ទាំងនោះចុះពីយានយន្ត ។

មាត្រា ១៩.- ទំនិញសង្គម ឬការដាក់ម្ហូបអាហារឲ្យនៅដោយឡែក

ម្ហូបអាហារស្រស់ៗ មិនត្រូវអនុញ្ញាតិអោយដឹកជញ្ជូនជាមួយសត្វរស់ទេ ។ ម្ហូបអាហារស្រស់ៗ ក៏មិនត្រូវអនុញ្ញាតិអោយដឹកជញ្ជូនជាមួយផលិតផលដទៃផ្សេងទៀត ដែលអាចបណ្តាលអោយមានឆ្លងមេរោគ ប៉ះពាល់ដល់អនាម័យ ឬធ្វើអោយ មានក្លិនអាក្រក់ លើកលែងតែម្ហូបអាហារស្រស់ៗទាំងនោះ មានការវេចខ្ចប់អោយបានត្រឹមត្រូវធ្វើយ៉ាងណាផ្តល់ការការពារ ទំនិញទាំងនោះអោយនៅល្អជាទីពេញចិត្ត ។

មាត្រា ២០.- ការបញ្ចេញ-បញ្ចូលខ្យល់

ការបញ្ចេញ-បញ្ចូលខ្យល់សមរម្យ ត្រូវផ្តល់ ឬធ្វើឡើង ដើម្បីរក្សាកំរិតជាតិសើមនៅក្នុងទំនិញដែលផ្ទុកក្នុងយានយន្តដឹកជញ្ជូន ។

មាត្រា ២១.- ការបង្ហូរទឹក

ប្រព័ន្ធបង្ហូរទឹកគ្រប់គ្រាន់ ចេញពីយានយន្ត ត្រូវផ្តល់ ឬធ្វើឡើង ដើម្បីបញ្ចេញ ឬដកចេញកំណកញើស ឬកំណកចំហាយទឹក និងការជោរទឹកឡើង ដើម្បីការពារទុកជាមុនការខូចខាត ចំពោះផលិតផលផ្ទាល់ និងបរិស្ថានជុំវិញ ។

មាត្រា ២២.- ពេលវេលាដឹកជញ្ជូន

ម្ហូបអាហារងាយខូចគុណភាព ត្រូវធ្វើការដឹកជញ្ជូនដោយមិនបង្អែរបង្អង់ឡើយ ។ ទំនិញទាំងនេះត្រូវទទួលបាននូវគុណប្រយោជន៍អំពីរបបអាទិភាព តាមលំដាប់លំដោយទំនិញនៃការជំរះបែបបទឆ្លងកាត់ព្រំដែន ដោយអនុលោមទៅតាមមាត្រា៩ (លំដាប់អាទិភាពនៃទំនិញសំរាប់ការជំរះបែបបទឆ្លងកាត់ព្រំដែន) នៃឧបសម្ព័ន្ធទី៤ (ការសំរួលនូវទំរង់បែបបទ ឆ្លងកាត់ព្រំដែន) នៃកិច្ចព្រមព្រៀង ។

មាត្រា ២៣.- សីតុណ្ហភាព

សីតុណ្ហភាពទំនិញត្រូវរក្សាអោយបានខ្ជាប់ខ្ជួន នៅតាមបណ្តោយផ្លូវនៃការធ្វើដំណើរ ដោយអនុលោមទៅតាមកំរិតបទដ្ឋាន(ស្តង់ដារ) អន្តរជាតិដែលមានចែងនៅក្នុងការកែសំរួលច្បាប់ចុងក្រោយនៃសៀវភៅណែនាំអំពីទំនិញងាយខូចគុណភាពរបស់សមាគមអន្តរជាតិដឹកជញ្ជូនតាមផ្លូវអាកាស និងកិច្ចព្រមព្រៀង ស្តីអំពីការដឹកជញ្ជូនជាអន្តរជាតិ នូវម្ហូបអាហារងាយខូចគុណភាព និងគ្រឿងចក្រពិសេសៗ ដែលប្រើប្រាស់សំរាប់ការដឹកជញ្ជូនទំនិញទាំងនោះ (ហៅកាត់ថា អាតេប៉េ) ចុះហត្ថលេខា នៅស៊ីណែវ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ ១៩៧០ ។

មាត្រា ២៤.- ការដឹកជញ្ជូនរុក្ខជាតិរស់ និងរុក្ខជាតិសំរាប់តុបតែងលំអ និងផ្កាកាត់

ក- សុខភាពរុក្ខជាតិ(ដំណាំ) : ការដឹកជញ្ជូនត្រូវបានគេដាក់កំហិតត្រឹមតែ រុក្ខជាតិ ឬដំណាំណាដែលមានសុខភាពល្អ គ្មានមេរោគ ។

ខ- វិយោគកម្ម ឬការដាក់ឱ្យនៅដាច់ដោយឡែក : ផ្កាកាត់ស្រស់ៗ ត្រូវដាក់នៅឱ្យដាច់ដោយឡែកចេញអំពីផ្លែឈើទុំ ស្លឹកឈើ-ស្លឹកផ្កា និងគ្រឿងតុបតែង និងប្រភពផ្សេងៗទៀតនៃឧស្ម័នអេទីឡែន ដែលវាជាហេតុឱ្យពុករលួយ ។

គ- ការវេច-ខ្ចប់ : រុក្ខជាតិរស់ ត្រូវវេចខ្ចប់នៅក្នុងកន្លែងបិទជិត ធ្វើយ៉ាងណាដើម្បីកាត់បន្ថយ សម្ងួត ការរំកិល ឬ រអិលចុះឡើង និងការខូចខាតក្នុងពេលដឹកជញ្ជូន និងផ្តល់ការបញ្ចេញ-បញ្ចូលខ្យល់ ។ល។

ឃ- ការផ្តល់ខ្យល់ចេញ-ចូល : រុក្ខជាតិរស់ត្រូវរក្សាទុកនៅក្នុងស្ថានភាពយ៉ាងណាឱ្យមានខ្យល់ចេញ-ចូលគ្រប់គ្រាន់ ។

ង- សំណើម : សំរាប់រុក្ខជាតិរស់ ការផ្ញើ ឬបញ្ជូនតាមកុងតឺន័រត្រូវរក្សាឱ្យមានភាពស្ងួត-ស្រស់ទឹក និងមិនត្រូវដាក់ឱ្យ នៅហាលក្នុងស្ថានភាពស្ងួតក្រៀងខ្លាំងពេកទេ ។ សំរាប់ផ្កាកាត់ស្រស់ៗ ត្រូវរក្សាសំណើមពាក់ព័ន្ធខ្ពស់បំផុត (ឧទាហរណ៍ពី ៩៥ភាគរយ ទៅ ៩៨ ភាគរយ) ត្រូវរក្សាដើម្បីចៀសវាងការស្ងួតខ្លាំងពេក ។

ច- សីតុណ្ហភាពៈ ការដឹកជញ្ជូនទំនិញតាមកុងតឺន័រ មិនត្រូវដាក់ចោលឱ្យត្រូវពន្លឺថ្ងៃ ស្ថានភាពកំដៅ ឬត្រជាក់ហួសហេតុពេកទេ ។ សីតុណ្ហភាពសមរម្យ ត្រូវបានរក្សាសំរាប់ផ្កាកាត់ស្រស់ៗ (ឧទាហរណ៍ប្រមាណជា ២អង្សាសេ ទៅ ៤អង្សាសេ និង ១០អង្សាសេ សំរាប់ ជំពូក ឬប្រភេទផ្កានៅតំបន់ត្រូពិក) ។

ឆ- ផ្លាកយីហោបញ្ជាក់ប្រភេទទំនិញៈ រុក្ខជាតិរស់ ត្រូវបិទផ្លាកយីហោ ឬផ្លាកសំគាល់ដែលជាប់មាំ មិនជ្រាបទឹក ឬជក់ ទឹក ដែលមានខ្លឹមសារ :

" LIVE PLANTS- NO EXTREME HEAT OR COLD " - រុក្ខជាតិរស់ - មិនត្រូវដាក់ឱ្យត្រូវកំដៅឬត្រជាក់ខ្លាំង ហួសហេតុ " ។

" THIS SIDE UP " ជ្រុងនេះត្រូវបញ្ឈរ- ជាមួយនឹងសញ្ញាព្រួញ បង្ហាញបញ្ជាក់អំពីពីជាន់លើត្រូវបិទ លាប ឬដាក់ ប្រើជានិច្ចនៅទីណាដែលសមរម្យ ។

ជ- ការស្រោចទឹក : ត្រូវប្រើទឹកស្អាត សំរាប់រក្សាទុករុក្ខជាតិរស់ និងរុក្ខជាតិតុបតែងលំអ និងផ្កាកាត់ ។

ជំពូកទី ៤
អវសានប្បញ្ញត្តិ

មាត្រា ២៥.- ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្មលើឧបសម្ព័ន្ធតាមរយៈគណៈកម្មាធិការរួម ។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆន្ទ ពីភាគីចុះកិច្ចសន្យាទាំងអស់ ។

មាត្រា ២៦.- ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម នៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា ។ ការអនុវត្តដូចគ្នានេះ ត្រូវបានគេយកមកប្រើក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធប្រសិនបើមាន ។

មាត្រា ២៧.- ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់វា នឹងត្រូវមានប្រសិទ្ធិភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធ ។ ការអនុវត្ត ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធប្រសិនបើមាន ។

មាត្រា ២៨.- ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារ នៃឧបសម្ព័ន្ធ ។

មាត្រា ២៩.- ការដាក់លក្ខខណ្ឌ

ការដាក់លក្ខខណ្ឌ ទៅលើឧបសម្ព័ន្ធ នឹងមិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ៣០.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុកជាបណ្ដោះអាសន្ន នូវការអនុវត្តឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែកដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការវិកវរជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន ។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀតភ្លាម តាមតែអាចធ្វើទៅបានអំពីការព្យួរទុក និងការបញ្ចប់ការព្យួរទុកនេះឱ្យបានឆាប់បំផុត នៅពេលណាដែលសភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ ។

មាត្រា ៣១.- ទំនាក់ទំនង ជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តគោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះ មិនអាចផ្ដាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះទេ ។ នៅក្នុងករណីដែលវិសមិតគ្នារវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀងនោះ កិច្ចព្រមព្រៀងត្រូវយកជាបានការ ។ នៅក្នុងករណីដែលវិសមិតរវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀត នោះវិសមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នានឹងកិច្ចព្រមព្រៀង ។

មាត្រា ៣២.- ទំនាក់ទំនង ជាមួយឯកសារភ្ជាប់នៃឧបសម្ព័ន្ធ

ឯកសារភ្ជាប់ ត្រូវបង្កើតជាផ្នែករួមបញ្ចូលគ្នាមួយ ជាមួយឧបសម្ព័ន្ធ និងត្រូវមានតំលៃចូលរួមស្មើៗគ្នា ។

មាត្រា ៣៣.- ការដោះស្រាយជំលោះ

ជំលោះ ឬទំនាស់រវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យានៅលើការបកស្រាយ ឬការអនុវត្ត ឧបសម្ព័ន្ធត្រូវស្រុះស្រួលគ្នា និងលើកយកមកដោះស្រាយដោយផ្ទាល់ ឬការចរចារដោយសន្តិវិធី តាមរយៈគណៈកម្មាធិការរួម ។

មាត្រា ៣៤.- ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាធរមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធ ដាច់ដោយឡែកចេញអំពីកិច្ចព្រមព្រៀងបានទេ ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធិប្រទានពេញលេញពីរាជរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ ទីក្រុងគុនមីង ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៥ ជា ០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា

តំណាងរាជរដ្ឋាភិបាលកម្ពុជា

ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម **ហ្វាង ជុនស៊ាន** រដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ឯកឧត្តម **សំពោង មង្គល់ទីឡៃ** រដ្ឋមន្ត្រីប្រៃសណីយ៍ ទូរគមនាគមន៍ ដឹកជញ្ជូន និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា

ឯកឧត្តម **សូ ថា** រដ្ឋមន្ត្រីអភិវឌ្ឍន៍ផែនការ និងសង្គមកិច្ច

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍

ឯកឧត្តម **ស៊ូរីយ៉ា រុងរឿងគិត** រដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ឯកឧត្តម **ប៊ុយ ឆាប៊ុង** អនុរដ្ឋមន្ត្រីកសិកម្ម និងអភិវឌ្ឍន៍ជនបទ

ឯកសារភ្ជាប់ : បញ្ជីនៃទំនិញខាយខូចគុណភាព

1. ម្ហូបអាហារ

1.1. ផលិតផលចេញពីរោងចក្រ (ចំណីអាហារស្រស់ ត្រជាក់ បង្កក)

1.2.1. ផ្លែឈើ និងបន្លែបង្ការស្រស់ៗ

1.2.2. ដំណាំកសិផល និងផលិតផលដំណាំកសិផលផ្សេងៗ

1.2. ផលិតផលពីសត្វ

1.2.1. សាច់សត្វ និងផលិតផលធ្វើអំពីសាច់សត្វ(ស្រស់ៗ ត្រជាក់ បង្កក)

1.2.1.1. សាច់គោ-សន្តានគោ

1.2.1.2. ផលិតផលសាច់សន្តានគោ

1.2.1.3. សាច់ជ្រូក-សាច់សន្តានជ្រូក

1.2.1.4. ផលិតផលពីសាច់ជ្រូក

1.2.1.5. សាច់បសុបក្សី(មាន់ ទា ក្ងាន ។ល។)

1.2.1.6. ផលិតផលអំពី សាច់បសុបក្សី(មាន់ ទា ក្ងាន ។ល។)

1.2.1.7. សាច់ចៀម និងពពែ

1.2.1.8. ផលិផលអំពីសាច់ចៀម និងពពែ

1.2.1.9. សាច់សេះ

1.2.1.10. ផលិតផលអំពីសាច់សេះ

1.2.1.11. សាច់សត្វផ្សេងទៀត

1.2.1.12. ផលិតផលអំពីសាច់សត្វផ្សេងទៀត

1.2.2. សត្វរស់ក្នុងទឹក និងផលិតផលអំពីសត្វរស់ក្នុងទឹក (ស្រស់ៗ ត្រជាក់ បង្កក ចំអិនរួច)

1.2.2.1. មច្ឆាជាតិ(ត្រី) សន្តវន្តជាតិ(បង្កង ក្តាម កំពឹស) សិប្បិសត្វ(គ្រុំ លាស ។ល។)និងសិរបាទសត្វ (សត្វមានជើង ឬប្រមោយនៅពីលើក្បាល ដូចជាមឹក-ឃឹហ៊ឹ ។ល។)

1.2.1.2. ផលិតផលអំពីមច្ឆាជាតិ(ត្រី) សន្តវន្តជាតិ(បង្កង ក្តាម.កំពឹស) សិប្បិសត្វ(គ្រុំ លាស ។ល។) និងសិរបាទសត្វ (សត្វមានជើង ឬប្រមោយនៅពីលើក្បាល ដូចជាមឹក-ឃឹហ៊ឹ។

1.2.2.3. សត្វដែលរស់នៅក្នុងទឹកផ្សេងទៀត

1.2.2.4. ផលិតផលអំពីសត្វដែលរស់នៅក្នុងទឹកផ្សេងទៀត

1.2.3. ទឹកដោះសត្វ និងផលិតផលធ្វើអំពីទឹកដោះសត្វ (ស្រស់ៗ ត្រជាក់ បង្កក ចំអិនរួច)

1.2.4. ស៊ុតសត្វ និងផលិផលធ្វើអំពីស៊ុតសត្វ (ស្រស់ៗ ត្រជាក់ បង្កក ចំអិនរួច)

2. **ទំនិញទាយខូចគុណភាព ដែលមិនមែនជាចំណីអាហារ**

2.1. **ផលិតផលចេញពីរោងចក្រ**

2.1.1. ផ្កាកាត់ស្រស់ៗ ឬត្រជាក់(ក្លាសេ)

2.1.2. រុក្ខជាតិរស់សំរាប់តុបតែងលំអ(ស្រស់)

2.1.3. រុក្ខជាតិរស់(វារីរុក្ខជាតិ) ដែលដុះក្នុងទឹក

2.1.4. ចំណែកនៃរុក្ខជាតិផ្សេងៗទៀត(ឧ. សំរាប់ការបង្កាត់ ឬបន្សាយ និងស្រាវជ្រាវ)

2.2. **ផលិតផលអំពីសត្វ**

2.2.1. សំណល់ ឬកំទេចកំទីសត្វ (សំរាប់យកសាច់)

2.2.2. អន្តការៈ(អការៈខាងក្នុង ឧ.ក្រពះ ខួរ សួត បេះដូង ។ល។) ឬសរីរាង្គសត្វ

2.2.3. សត្វដែលព្រលាត់ស្បែកហើយវះពោះ តែមិនទាន់កាត់ជាដុំ ឬកង់ - គ្រោងឆ្អឹង-ខ្លួនសត្វ

2.2.4. ឈាមសត្វ

2.2.5. ស្បែក និងផ្ទាំងស្បែកសត្វធំៗ

2.2.6. ស៊ុតសត្វសំរាប់ភ្ញាស់

2.2.7. ទឹកកាម ទឹកអសុចិ និងក្រូណា (កូនសត្វមិនទាន់ញាស់ ឬកើត ដែលនៅក្នុងស្បូន-អំប្រីយ៉ុ)

2.3. **មុខទំនិញសំរាប់ខាងវេជ្ជសាស្ត្រ និងពេទ្យសត្វ(ដាក់ឱ្យត្រជាក់ និងបង្កក)**

2.3.1. ឈាម ទឹកឈាម(លោហិតម្តុ) និងសេរ៉ូម

2.3.2. ថ្នាំចាក់បង្ការរោគ-វ៉ាក់សាំង

2.3.3. ភ្នាក់ងារ ឬសារធាតុចំលង ឬកតាលីករ(វីរ៉ុស) នៃមន្ទីរពិសោធន៍ជីវសាស្ត្រ

2.3.4. សំភារៈសំរាប់គោលបំណង ស្រាវជ្រាវ និងវិនិច្ឆ័យ ខាងរោគសាស្ត្រ ជីវសាស្ត្រ និងសេរ៉ូមសាស្ត្រ (វិជ្ជាសាស្ត្រធ្វើសេរ៉ូម)

3. **សត្វរស់**

3.1. គោ ក្របី បសុសត្វធំៗ

3.2. ចៀម និងពពែ

3.3. ជ្រូក

3.4. ទន្សាយ

3.5. បសុបក្សី(មាន់ ទា ក្ងាន ។ល។) បក្សីចិញ្ចឹម

3.6. សត្វស្លាប-បក្សី

3.7. សេះ

3.8. សត្វរស់ក្នុងទឹក

3.9. សត្វចិញ្ចឹមលេង (ឧ. ឆ្កែ ឆ្មា ។ល។

3.10. សត្វចិញ្ចឹមសំរាប់មន្ទីរពិសោធន៍

3.11. សត្វចិញ្ចឹមសំរាប់មើលកំសាន្តជាសាធារណៈ

3.12. សត្វចិញ្ចឹមសំរាប់សួនសត្វ

3.13. ជង្រុកនាង

3.14. ឃ្មុំ

3.15. សត្វចិញ្ចឹមផ្សេងទៀត

ANNEX 3: CARRIAGE OF PERISHABLE GOODS

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed at Vientiane on 26 November 1999, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China at Phnom Penh on 3 November 2002, and acceded to by the Union of Myanmar at Dali City on 19 September 2003, and amended at Phnom Penh on 30 April 2004 (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Articles 3(m) and 10(b) of the Agreement, calling for this Annex to provide technical details,

HAVE AGREED AS FOLLOWS:

Part I: General Provisions

Article 1: Definition

For the purpose of this Annex, "Perishable Goods" shall mean organic substances or living organisms that are vulnerable to easy deterioration beyond marketability or to death under the combined effect of duration and conditions of transport such as temperature (heat or cold), humidity or draught, or movement.

Article 2: Priority Regime

(a) Perishable Goods listed in the Attachment shall be granted a priority border crossing clearance regime according to the order set out in Article 9 of Annex 4 to the Agreement.. This list may be modified from time to time subject to agreement by the Contracting Parties through the Joint Committee.

(b) For the purpose of transport facilitation, the Contracting Parties shall inform each other of their respective lists of Perishable Goods for which quarantine clearance can be expedited, and any changes thereof, through the points of contact called for in Article 4(b) of this Annex.

Article 3: Health, Sanitary and Phytosanitary Requirements and Documentation

Perishable goods shall be transported across the border only if they meet the relevant national health, sanitary and/or phytosanitary regulation(s) and are accompanied by the relevant national health, sanitary and/or phytosanitary certificate(s)/document(s). Relevant parts of both requirements shall be in accordance with Article 9 of the Agreement.

Article 4: Institutional Mechanism

(a) The Contracting Parties shall coordinate their activities for the implementation of this Annex, and resolve any issues arising therefrom through the Health/Sanitary and Phytosanitary Sub-committee of the Joint Committee, established on 30 April 2004 in Phnom Penh, and other such mechanisms between and among them.

(b) The Contracting Parties shall notify each other of their respective points of contact for the implementation of this Annex, and of any changes thereof.

Article 5: Standards for Particular Categories of Perishable Goods

For two particular categories of perishable goods, i.e., (a) live animals, and (b) perishable foodstuffs for human consumption, live and ornamental plants, and cut flowers, this Annex provides more detailed transportation standards.

Article 6: Recommendatory Nature of Standards

Parts II and III of this Annex provide recommendations that may serve as guidance for the Contracting Parties in their regulation of the cross-border carriage of (a) live animals, and (b) perishable foodstuffs for human consumption, live and ornamental plants, and cut flowers.

Part II: Live Animals

Article 7: Scope of Application

This Part should apply to the cross-border carriage of live animals by road transport vehicles.

Annex 3: Carriage of Perishable Goods

Article 8: Fitness

An animal should be transported only if it is fit for the intended journey. An animal that is ill or injured should not be considered fit for transportation. The same goes for animals in the perinatal period.

Article 9: Marking of the Means of Transportation

Vehicles and containers in which animals are transported should be marked with a symbol indicating the presence of live animals and a sign indicating the animals' upright position.

Article 10: Comfort, Safety, and Hygiene

(a) Animals should not be transported in a way that may cause injury or unnecessary suffering of that animal. Care should be taken not to subject the animals to sudden changes of speed or direction.

(b) The means of transportation should be easy to clean, escape-proof, and so constructed and operated as to withstand the weight of the animals, to avoid injury and unnecessary suffering, and to ensure their safety during transport.

(c) Animals should be loaded in means of transportation that are equipped with a dropping collecting device and that have been thoroughly cleaned and where appropriate disinfected.

(d) Dead animals, litter, and droppings should be removed as soon as possible and disposed of in accordance with relevant national health/sanitary regulations.

(e) Lactating animals not accompanied by their suckling young should be milked at intervals of about 12 hours.

Article 11: Space Requirements

Animals should be provided with adequate space in the means of transport so that they may stay in their natural position (standing, sitting, or lying down as the case may be) and when necessary, with partitions to protect them from motion of the means of transport. The loading density should allow sufficient ventilation and air space.

Article 12: Shelter and Ventilation

The means of transport should be constructed and operated so as to protect animals against inclement, extreme, or unfavorable weather conditions and marked differences in atmospheric conditions. Among other things, they should be equipped with a roof and a sufficient number of vents or other means of ensuring that it is adequately ventilated.

Article 13: Segregation

(a) Animals that are naturally hostile to each other because of group, age, sex, or origin should be kept separated from each other.

(b) Animals with different sanitary requirements should not be transported in the same means of transport.

(c) Animals transported should be segregated from persons or other species of animals.

Article 14: Care and Medical Treatment

(a) Appropriate care is to be administered to the animal transported.

(b) Animals fallen ill or injured en route should receive first aid treatment as soon as possible; they should be given appropriate veterinary treatment and, if necessary, undergo emergency slaughter in accordance with relevant national health/sanitary regulations.

(c) Sedation should not be administered, unless in exceptional circumstances and then only under the direct supervision of a veterinarian.

Article 15: Inspection Arrangements

The means of transport should allow easy observation and inspection of the animals contained therein (e.g., via a window or hatch).

Article 16: Transport Time

(a) Animals should be transported without delay. The Contracting Parties should make arrangements in order to expedite the transport of live animals. Live animal consignments should benefit from a priority regime in the border clearance order according to Article 9 of Annex 4 to the Agreement.

(b) For journeys exceeding 24 hours, the itinerary is to be chosen so as to allow a staging point, where the animals are rested, fed, and watered, and if necessary unloaded and given accommodation. Places and duration of time for unloading animals should be defined in accordance with relevant national health/sanitary regulations.

Part III: Perishable Foodstuffs and Other Perishable Commodities

Article 17: Scope of Application

This Part should apply to the cross-border carriage by road transport vehicle of perishable foodstuffs for human consumption, live and ornamental plants, and cut flowers.

Article 18: Hygiene of Means of Transportation

(a) The inside surfaces of the means of transportation should be finished in such a way that they resist corrosion and are inert vis-à-vis the products carried and do not transfer substances to the products carried. They should be smooth and constructed of a material that is waterproof, easy to clean and to disinfect.

(b) Except for the required ventilation and water drainage, the cargo hold should allow the hermetic and watertight closing so as to avoid the inward or outward

movement of dust, dirt, soil, and pests (e.g., microbes, vermin, insects), and to protect the products and the surrounding environment from mutual influences, contamination, and impairment. Any required ventilation and water drainage should be designed so as to take place in a closed circuit.

(c) The means of transportation used for perishable foodstuffs should not be used for conveying live animals or other products that may be detrimental to or contaminate the foodstuff unless they have, after unloading of those products, been thoroughly cleansed, disinfected, and where necessary deodorized.

Article 19: Segregation

Fresh foodstuffs should not be transported with live animals. Fresh foodstuffs should also not be transported with other products that may contaminate, affect their hygiene, or give them a smell, unless the fresh foodstuffs are packaged in such a way as to provide satisfactory protection.

Article 20: Ventilation

Appropriate ventilation should be provided to regulate the degree of humidity in the cargo hold.

Article 21: Drainage

Adequate drainage should be provided in order to evacuate the condensation and melting water so as to prevent damage to the products and the environment.

Article 22: Transport Time

Perishable foodstuffs should be transported without delay. They should benefit from a priority regime in the border clearance order according to Article 9 of Annex 4 to the Agreement.

Article 23: Temperature

The temperature of the cargo should be maintained throughout the journey in accordance with international standards, such as those set out in the latest edition of the Perishable Cargo Manual of the International Air Transport Association and the Agreement on the International Carriage of Perishable Foodstuffs and on the Special Equipment to be Used for Such Carriage ("ATP"), Geneva, 1 September 1970.

Article 24: Transportation of Live and Ornamental Plants and Cut Flowers

(a) Plant Health: Transportation should be restricted to only healthy pest-free plants.

(b) Segregation: Fresh cut flowers should be segregated from ripening fruits, leaves, and trimmings and other sources of ethylene gas, which induces their decay.

(c) Packaging: Live plants should be packaged in a filling compound, in a manner to minimize desiccation, movement, and damage during transport and to allow ventilation.

(d) Ventilation: Live plants should be stored in such a manner that they have adequate ventilation.

(e) Humidity: For live plants, shipment containers should be kept dry and not be exposed to desiccating conditions. For fresh cut flowers, a high relative humidity (e.g., 95% to 98%) should be maintained in order to avoid drying out.

(f) Temperature: Shipment containers should not be left exposed to the sun, extreme heat, or freezing conditions. Appropriate temperature should be maintained for fresh cut flowers (e.g., 2°C to 4°C, and 10°C for tropical species).

(g) Labeling: Live plants should be provided with durable waterproof labels or tags stating:

"LIVE PLANTS – NO EXTREME HEAT OR COLD" on all sides and top. The label or tag should be completed with appropriate restrictions.

"THIS SIDE UP" with arrows indicating the top should always be used where appropriate.

(h) Watering: Clean water should be used to store live and ornamental plants and cut flowers.

Part IV: Final Provisions

Article 25: Amendment

Any Contracting Party may propose amendments to the Annex via the Joint Committee. Such amendments shall be subject to the unanimous consent of the Contracting Parties.

Article 26: Ratification or Acceptance

The Annex is subject to ratification or acceptance of the Governments of the Contracting Parties. The same applies to an amendment to the Annex, if any.

Article 27: Entry into Force

The Annex will enter into force on the day that at least two Contracting Parties have ratified or accepted it, and will become effective only among the Contracting Parties that have ratified or accepted it. The same applies to an amendment to the Annex, if any.

Article 28: Conforming National Law

Where necessary, the Contracting Parties undertake to conform their relevant national legislation with the contents of the Annex.

Annex 3: Carriage of Perishable Goods

Article 29: Reservations

No reservation to the Annex shall be permitted.

Article 30: Suspension of the Annex

Each Contracting Party may temporarily suspend wholly or partly the application of the Annex with immediate effect in the case of emergencies affecting its national safety. The Contracting Party will inform the other Contracting Parties as soon as possible of such suspension, which will end as soon as the situation returns to normal.

Article 31: Relationship with the Agreement

As a measure to implement the principles laid down in the Agreement, the Annex cannot depart from or be contrary to these principles. In case of incompatibility between the Annex and the Agreement, the latter shall prevail. In case of incompatibility between the Annex and another annex or protocol, such incompatibility shall be interpreted in light of the Agreement.

Article 32: Relationship of the Attachment to the Annex

The attachment shall form an integral part of the Annex and shall be equally binding.

Article 33: Dispute Settlement

Any dispute between or among two or more Contracting Parties on the interpretation or application of the Annex shall be settled directly or by amicable negotiation in the Joint Committee.

Article 34: Denunciation

Once entered into force, the Annex cannot be denounced separately from the Agreement.

Attachment: List of Perishable Goods

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Kunming on 5 July 2005 in six originals in the English language.

Signed:

For the Royal Government of Cambodia

....

His Excellency Sun Chanthol
Minister of Public Works and Transport

For the Government of the People's Republic of China

....

His Excellency Zhang Chunxian
Minister of Communications

For the Government of the Lao People's Democratic Republic

....

His Excellency Somphong Mongkhonvilay
Minister to Prime Minister's Office

For the Government of the Union of Myanmar

....

His Excellency Soe Tha
Minister of National Planning and Economic Development

For the Government of the Kingdom of Thailand

....

His Excellency Suriya Jungrungreangkit
Minister of Transport

For the Government of the Socialist Republic of Viet Nam

....

His Excellency Bui Ba Bong
Vice Minister of Agriculture and Rural Development

Attachment to Annex 3: List of Perishable Goods

ATTACHMENT: LIST OF PERISHABLE GOODS

1. Foodstuffs

1.1 Plant Products (fresh, chilled, frozen)

1.1.1 Fruits and vegetables

1.1.2 Other crops and crop products

1.2 Animal Products

1.2.1 Meat and meat products (fresh, chilled, frozen, cooked)
1.2.1.1 Bovine meat
1.2.1.2 Bovine meat products
1.2.1.3 Porcine (swine) meat
1.2.1.4 Porcine meat products
1.2.1.5 Poultry meat
1.2.1.6 Poultry meat products
1.2.1.7 Lamb/sheep and goat meat
1.2.1.8 Lamb/sheep and goat meat products
1.2.1.9 Horse meat
1.2.1.10 Horse meat products
1.2.1.11 Other meat
1.2.1.12 Other meat products

1.2.2 Aquatic animals and aquatic animal products (fresh, chilled, frozen, cooked)
1.2.2.1. Fish, crustacean, molluscs, and cephalopods
1.2.2.2. Fish, crustacean, mollusc, and cephalopod products
1.2.2.3. Other aquatic animals
1.2.2.4. Other aquatic animal products

1.2.3 Dairy and dairy products (fresh, chilled, frozen, pasteurized)

1.2.4 Egg and egg products (fresh, chilled, frozen, cooked)

2. Non-Foodstuffs

2.1 Plant Products

2.1.1 Cut fresh or chilled flowers
2.1.2 Live ornamental plants
2.1.3 Live aquatic plants
2.1.4 Other plant parts (e.g., for propagation or research)

2.2 Animal Products

2.2.1 Offal
2.2.2 Viscera (organs)
2.2.3 Carcass
2.2.4 Blood
2.2.5 Skin and hide
2.2.6 Hatching eggs
2.2.7 Semen and embryo

Attachment to Annex 3: List of Perishable Goods

2.3 Medical and Veterinary Items (refrigerated and frozen)

2.3.1 Blood, blood plasma, and serum
2.3.2 Vaccines
2.3.3 Biological laboratory reagents
2.3.4 Pathological, biological, and serological materials for research and diagnostic purpose

3. Live Animals

3.1 Cattle and Buffalo
3.2 Sheep and Goats
3.3 Pigs
3.4 Rabbits
3.5 Poultry
3.6 Birds
3.7 Horses
3.8 Aquatic Animals
3.9 Pets (e.g., dogs and cats)
3.10 Laboratory Animals
3.11 Animals for Public Entertainment
3.12 Zoo Animals
3.13 Silkworms
3.14 Bees
3.15 Other Live Animals

ឧបសម្ព័ន្ធទី ៥

ការដឹកជញ្ជូនពលរដ្ឋឆ្លងកាត់ព្រំដែន

ANNEX 5

CROSS-BORDER MOVEMENT OF PEOPLE

ឧបសម្ព័ន្ធទី ៥

ការដឹកជញ្ជូនពលរដ្ឋឆ្លងកាត់ព្រំដែន

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍

និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីអំពីការសំរបសំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាត់ថា " ឧបសម្ព័ន្ធ ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម (តទៅហៅកាត់ថា " ភាគីចុះកិច្ចសន្យា ") ។

យោង កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅទីក្រុងវៀងច័ន្ទ និងធ្វើវិសោធនកម្ម នាថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងយ៉ាងហ្គូន ដែលបានយល់ព្រមចូលដោយព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងយ៉ាងហ្គូន នាថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូលដោយសហភាពមីយ៉ាន់ម៉ា នាថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា " កិច្ចព្រមព្រៀង " ។

យោង មាត្រាទី ៣(បេ) និង(អិន) នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេសទៅតាមទីកន្លែងហើយ ដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា ។

យោង មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ។

យោង កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានីលឡា ក្នុងខែមករា ឆ្នាំ២០០០ កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ២០០២ និងកិច្ចប្រជុំលើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញក្នុងខែកញ្ញា ឆ្នាំ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀងនិងឧបសម្ព័ន្ធ-ពិធីសាររបស់វាក្នុងឆ្នាំ ២០០៥ ។

យោង មាត្រា ៥ និង ៦ នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យឧបសម្ព័ន្ធនេះ ចែងលំអិតអំពីផ្នែកបច្ចេកទេស ។

បានប្រកាសឱ្យប្រើច្បាប់ដូចតទៅនេះ :

ជំពូកទី ១
លក្ខខណ្ឌទូទៅ

មាត្រា ១.- និយមន័យ

និយមន័យនៃពាក្យទាំងឡាយ ដែលមានគូសបន្ទាត់ខាងក្រោម ត្រូវអនុវត្ត សំរាប់គោលបំណង នៃឧបសម្ព័ន្ធនេះ :

ក- __ភារៈវត្ថុ ឬឥវ៉ាន់យកជាប់តាមខ្លួន__ : គឺជាភារៈវត្ថុដែលធ្វើដំណើរ ជាមួយអ្នកដំណើរ នៅលើមធ្យោបាយ ឬយានយន្តតែមួយ ជាមួយអ្នកដំណើរ ។

ខ- __អ្នកដឹកជញ្ជូន__ : គឺជាបុគ្គលដែលធ្វើការដឹកជញ្ជូន ដើម្បីទទួលរង្វាន់ ឬបានផលកំរៃ ឬមិនយកថ្លៃនៅក្នុងក្របខ័ណ្ឌធុរកិច្ច ឬកិច្ចការជំនួញរបស់ខ្លួន នូវអ្នកដំណើរ និងភារៈវត្ថុរបស់គេ ប្រសិនបើមាន ។

គ- __ការយឺតយ៉ាវ__ : គឺជាការយឺតយ៉ាវក្នុងសកម្មភាពនៃការដឹកជញ្ជូននៅពេលដែលវាមិនបានទៅដល់ចំណុចគោលដៅ នៅក្នុងអំឡុងពេលដែលបានព្រមព្រៀងគ្នា ឬប្រសិនបើមិនមានការព្រមព្រៀងដូចនេះ នោះគឺជាអំឡុងពេលវេលាធម្មតា ដែលត្រូវការសំរាប់អ្នកដឹកជញ្ជូនដែលបានប្រគល់សិទ្ធិតាមកាលកំណត់មួយ នៅក្នុងស្ថានភាព ឬល័ក្ខខ័ណ្ឌដូចគ្នា ។

ឃ- __ប្រធានស័ក្តិ__ : ព្រឹត្តិការណ៍ទាំងឡាយ ដែលបណ្តាលឱ្យមានការបាត់បង់ ខូចខាត ឬយឺតយ៉ាវ ដែលអ្នកដឹកជញ្ជូន មិនអាចដឹងបានជាមុន ឬចៀសវាងបាន និងជាបច្ច័យ ឬផលវិបាក ដែលអ្នកដឹកជញ្ជូនមិនអាចបង្ការការពារ ឬគ្រួតត្រាបាន ។

ង- __ឥវ៉ាន់ ឬភារៈវត្ថុយួរដៃ__ : គឺជាឥវ៉ាន់ ឬភារៈវត្ថុដែលរក្សាទុកដោយអ្នកដំណើរខ្លួនឯងផ្ទាល់នៅក្នុងពេលដឹកជញ្ជូន ។

ច- __អ្នកដំណើរ__ : គឺជាបុគ្គលណា ដែលនៅក្នុងសកម្មភាពនៃកិច្ចសន្យាដឹកជញ្ជូនមួយ ដែលធ្វើឡើងដោយអ្នកដំណើរ ឬ ដោយក្នុងនាមនៃអ្នកដំណើរ ត្រូវបានគេដឹកជញ្ជូនដោយអ្នកដឹកជញ្ជូនណាម្នាក់ ដើម្បីទទួលបានជារង្វាន់-ប្រាក់កំរៃ ឬមិនយកថ្លៃនៅក្នុងក្របខ័ណ្ឌធុរកិច្ច ឬកិច្ចការជំនួញរបស់អ្នកដឹកជញ្ជូន ។

ឆ- __ឥវ៉ាន់ ឬភារៈវត្ថុចុះបញ្ជី__ : ឥវ៉ាន់ ឬភារៈវត្ថុ របស់អ្នកដំណើរ ដែលទទួលរក្សាទុកដោយអ្នកដឹកជញ្ជូនក្នុងគោលបំណងដឹកជញ្ជូន ។

ឈ- **កំណត់សំគាល់** : សេចក្តីទាំងឡាយ ដែលធ្វើឡើងដោយអ្នកដឹកជញ្ជូន ឬអ្នកដំណើរ ទៅតាមស្ថានភាពនៃឥវ៉ាន់ឬភារៈវត្ថុ នៅក្នុងពេលទទួលចុះបញ្ជី ឬពេលចែកចាយ ។

ញ- **សិទ្ធិគណនាពិសេស** Special Drawing Right(SDR) : គឺជាឯកតានៃគណនីមួយ ដែលកំណត់ដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund)។ ការប្តូររូបិយវត្ថុមួយចំនួនទៅជារូបិយវត្ថុជាតិ ត្រូវគណនាដោយអនុលោមទៅតាមនិតិវិធីក្នុងការប៉ាន់ប្រមាណតំលៃដែលអនុវត្តដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ។

ដ- **ប្រតិបត្តិករដឹកជញ្ជូន** : គឺជាអ្នកដឹកជញ្ជូន គឺជានិតិបុគ្គល ឬបុគ្គលធម្មតាជាឯកជន ឬជាសាធារណជន ដែលជាអ្នកដឹកជញ្ជូនទំនិញ និង/ឬ អ្នកដំណើរតាមផ្លូវគោក សំរាប់ទទួលរង្វាន់ជាប្រាក់កំរៃ ។

ឋ- **ឥវ៉ាន់ ឬភារៈវត្ថុ មិនយកជាប់តាមខ្លួន** : ជាឥវ៉ាន់ ឬភារៈវត្ថុ ដែលដឹកជញ្ជូនរបៀបដូចជាទំនិញធម្មតា ដែលមិនស្ថិតនៅលើមធ្យោបាយ ឬយានយន្តតែមួយជាមួយអ្នកដំណើរទេ ។

ផ្នែកទី ២

ការត្រួតពិនិត្យអន្តោប្រវេសន៍ សុខភាព និងគយរដ្ឋាករ

មាត្រា ២.- ឯកសារ និងទិដ្ឋាការធ្វើដំណើរដែលមានសុពលភាព

ក- លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរជាអន្តរជាតិ សំរាប់មនុស្សម្នា (ពលរដ្ឋ) ឆ្លងកាត់ព្រំដែន

ពលរដ្ឋធ្វើដំណើរឆ្លងកាត់ព្រំដែន ត្រូវយកជាប់ខ្លួន នូវលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរជាអន្តរជាតិដែលជំនួសលិខិតឆ្លងដែនមានសុពលភាពមួយ ។ ភាគីចុះកិច្ចសន្យានិមួយៗត្រូវផ្តល់ឱ្យភាគីចុះកិច្ចសន្យាដទៃទៀតនូវគំរូ នៃលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរជាអន្តរជាតិដែលជំនួសលិខិតឆ្លងដែនតាមផ្លូវការទូត ។ ពលរដ្ឋធ្វើការឆ្លងកាត់ព្រំដែនត្រូវមានទិដ្ឋាការដែលជាតំរូវការរបស់ប្រទេសជាម្ចាស់ផ្ទះ លើកលែងតែមានការលើកលែងទិដ្ឋាការ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬប្បញ្ញត្តិច្បាប់ និងយុត្តាធិការទាំងឡាយ នៃប្រទេសជាម្ចាស់ផ្ទះ ។

ខ- លក្ខខ័ណ្ឌ និងនិតិវិធី នៃការចេញទិដ្ឋាការ

១ - លក្ខខ័ណ្ឌទូទៅសំរាប់ពលរដ្ឋធ្វើការឆ្លងកាត់ព្រំដែន :

- ទំរង់បែបបទនៃការចេញឱ្យ លក្ខខ័ណ្ឌ និតិវិធី ប្រភេទ និងភិនភាគលក្ខណៈ នៃទិដ្ឋាការ ត្រូវជាកម្មវត្ថុ ស្របទៅតាមច្បាប់និងបទប្បញ្ញត្តិ យុត្តាធិការទាំងឡាយនៃប្រទេសជាម្ចាស់លើកលែងតែការបញ្ជាក់ក្នុងឧបសម្ព័ន្ធនេះ ។

- រយៈពេលនៃការចេញច្បាប់ឱ្យ ឬការបដិសេធផ្តល់ទិដ្ឋាការមួយ មិនត្រូវឱ្យលើសពីរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការឡើយ ។

២- លក្ខខ័ណ្ឌពិសេស សំរាប់អ្នកបើកបរ /យានិក នៃយានយន្តធ្វើពាណិជ្ជកម្មផ្លូវគោកទាំងឡាយ (តទៅហៅកាត់ថា យានិក/អ្នកបើកបរ):

- រយៈពេលនៃសុពលភាពទិដ្ឋាការ : ប្រទេសជាសាមីត្រូវចេញ នូវទិដ្ឋាការចូល/ចេញច្រើនដង (មិនកំណត់ចំនួន) មួយសំរាប់រយៈពេលសុពលភាពមួយឆ្នាំឱ្យអ្នកបើកបរ/យានិកទាំងឡាយ ។ រយៈពេលតិចជាងនេះ នៃអំឡុងពេលសុពលភាពអាចត្រូវគេអនុញ្ញាតិឱ្យបាន ដោយអនុលោមទៅតាមសំណើររបស់អ្នកសុំ ។

- ឯកសារជាតំរូវការទាំងឡាយសំរាប់គាំទ្រការអនុវត្ត : ការស្នើសុំទិដ្ឋាការមួយដោយ អ្នកបើកបរ ឬយានិក ត្រូវមានឯកសារយោងភ្ជាប់មកជាមួយ ដូចជាវិញ្ញាបនប័ត្រវិជ្ជាជីវៈ ដែលចេញអោយដោយប្រតិបត្តិករដឹកជញ្ជូនដែលមានការអនុញ្ញាតមួយនៃប្រទេសសាមី ដែលមានអជ្ញាប័ណ្ណដោយ អនុលោម ទៅតាមតំរូវការ នៃឧបសំព័ន្ធទី៩ នៃកិច្ចព្រមព្រៀង ។ អ្នកស្នើសុំដែលជាអ្នកបើកបរ ត្រូវដាក់ភ្ជាប់ជាមួយផងដែរ នូវច្បាប់ថតចំលង នៃប័ណ្ណបើកបររថយន្ត ០១ ច្បាប់របស់ខ្លួន ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើម ស្របទៅតាមឧបសំព័ន្ធទី ១៦ នៃកិច្ចព្រមព្រៀង ។

គ- លិខិតឆ្លងដែន

រាល់ចំណុចពិសេសៗទាំងឡាយ ដែលមាននៅក្នុងលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរជាអន្តរជាតិដែលជំនួសលិខិតឆ្លងដែន ឬទិដ្ឋាការ ត្រូវសរសេរបន្ថែមពីលើភាសាជាតិ ជាភាសាអង់គ្លេស ។

មាត្រា ៣.. ការត្រួតពិនិត្យសុខភាពពលរដ្ឋ

ក- លក្ខណៈទូទៅ : ប្រទេសសាមីត្រូវអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ខ្លួនអោយស្របទៅតាម "បទប្បញ្ញត្តិសុខភាពអន្តរជាតិ " នៃការអនុវត្តរបស់អង្គការសុខភាពពិភពលោក (WHO) ។

ខ- គោលការណ៍ : មិនធ្វើការត្រួតពិនិត្យជាបទប្បញ្ញត្តិ សំរាប់អ្នកដំណើរដែល :

១- កាន់មកជាមួយ នូវឯកសារបញ្ជាក់សុខភាព របស់អង្គការសុខភាពពិភពលោក(WHO) ។

២- មិនចេញមកពី ឬឆ្លងកាត់ តំបន់ដែលគេប្រកាសថាមានឆ្លងមេរោគ ឬតំបន់ហានិភ័យ ។ និង

៣- ជាជនដែលមិនបានបង្ហាញថាមានអាការៈរោគ-រោគសញ្ញាខាងក្រៅនៃជំងឺឆ្លងរាលដាលណាមួយ ដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ។

៤- នឹងមិនត្រូវស្ថិតនៅក្រោមកម្មវត្ថុនៃការពិនិត្យសុខភាព ការត្រួតពិនិត្យតាមដាន និងការឆែកពិនិត្យខាងវេជ្ជសាស្ត្រជាប្រចាំឡើយ ។

គ-ការលើកលែង : ការលើកលែងចេញពីការត្រួតពិនិត្យសុខភាព អាចអនុញ្ញាត្តិបាន ក្នុងករណីពិសេស ។

ពលរដ្ឋដែលស្ថិតនៅក្រោម(ឬជាកម្មវត្ថុនៃ) ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ គឺជាជនទាំងឡាយណាដែល :

១- មិនបានកាន់មកជាមួយ ឯកសារសុខភាព ចេញដោយអង្គការសុខភាពពិភពលោក(WHO)

២- ជនណាដែល ចេញមកពី ឬឆ្លងកាត់ តំបន់ដែលគេប្រកាសថាមានឆ្លងមេរោគ ឬតំបន់ហារនិភ័យ ។ និង

៣- ជនដែលបានបង្ហាញអោយឃើញថាមានអាការៈរោគ-រោគសញ្ញាខាងក្រៅ នៃជំងឺឆ្លងរាលដាលណាមួយដែលធ្វើ ឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ។

ឃ- ប្រតិកម្ម ឬសកម្មភាពភ្លាមៗ នៅពេលពិនិត្យឃើញ បុគ្គលដែលមានចំលងមេរោគ

នៅពេលណាក៏ដោយ ដែលអ្នកដំណើរម្នាក់ តាមរយៈការត្រួតពិនិត្យខាងវេជ្ជសាស្ត្របានរកឃើញថា បានឆ្លងមេរោគនៃជំងឺឆ្លងរាលដាលណាមួយដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធអាច :

១- បដិសេធការចូលទៅក្នុងទឹកដីរបស់ខ្លួន ឬក៏ប្រាប់ត្រឡប់ទៅវិញជនបរទេសទាំងនោះប្រសិន បើស្ថានភាពសុខភាពរបស់ពួកគេ អាចឱ្យគេធ្វើដំណើរត្រលប់ទៅវិញបាន និងទូន្មានគេឱ្យត្រឡប់ទៅប្រទេសដើមវិញ ។

២- ប្រសិនបើស្ថានភាពសុខភាពរបស់ពួកគេមិនអាចឱ្យពួកគេធ្វើដំណើរបាន ត្រូវផ្តល់ការថែទាំនិងព្យាបាលខាងវេជ្ជសាស្ត្រសមរម្យ ដោយការដាក់បុគ្គលនោះអោយនៅដាច់ពីគេ ។

៣- ធ្វើការកត់សំគាល់យ៉ាងរហ័សជូនទៅអង្គការសុខភាពពិភពលោកតាមរយៈការទំនាក់ទំនងដ៏សមរម្យ ដោយស្របទៅតាមបទបញ្ញត្តិដែលអាចធ្វើបាន ។

ង- ឯកសារសុខភាព : ពលរដ្ឋទាំងឡាយ ត្រូវបានស្នើអោយមាន កាន់ឯកសារសុខភាពផ្ទាល់ខ្លួន ដែលផ្តល់អោយដោយអង្គការសុខភាពពិភពលោក (WHO) (ឧ. វិញ្ញាប័នបត្រ បញ្ជាក់ការចាក់វ៉ាក់សាំងការពារជម្ងឺគ្រុនលឿង ។ល។)

មាត្រា ៤.- ការត្រួតពិនិត្យគយ នៃទ្រព្យសម្បត្តិប្រើប្រាស់ផ្ទាល់ខ្លួនៈ ការអនុញ្ញាតអោយរួចពីការបង់ពន្ធ

ក- ការនាំចូលបណ្តោះអាសន្ន

១- ការនាំចូលជាបណ្តោះអាសន្ន នូវទ្រព្យសម្បត្តិប្រើប្រាស់ផ្ទាល់ខ្លួន ដោយបុគ្គលឯកជនត្រូវបានគេលើកលែង អំពីពន្ធគយ និងអាករទាំងឡាយនៅក្នុងប្រទេសសាមី ជាកម្មវត្ថុក្នុងការនាំចេញទៅវិញ ក្នុងអំឡុងពេលអនុញ្ញាតឱ្យ

ស្នាក់នៅ និងដោយមិនមានរងនូវការផ្លាស់ប្តូរណាមួយ ដែលផ្សេងអំពីការចុះថ្លៃ និង/ឬការប្រើប្រាស់ ។ ដូចគ្នានេះផងដែរ ការនាំចេញទៅវិញនៅក្នុងស្ថានភាពដដែល(ដោយមិនមានការផ្លាស់ប្តូរផ្នែកឬគ្រឿងបន្សំណាមួយ) ដោយ ការផ្តល់ត្រលប់ទៅវិញជូនពលរដ្ឋទាំងឡាយ នៅក្នុងប្រទេសដើមរបស់គេនូវទ្រព្យសម្បត្តិប្រើប្រាស់ផ្ទាល់ខ្លួនដែលពួកគេបានយកតាមខ្លួន នៅក្នុងពេលចេញដំណើរពីប្រទេសដើមរបស់គេ ហើយត្រូវរួចចេញពីពន្ធគយ និងអាករផ្សេងទៀត ។

២- សំរាប់គោលបំណងនៃបទប្បញ្ញត្តិនេះ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងឡាយ ត្រូវមានន័យ ជាអង្គវត្ថុទាំងឡាយ(ថ្មី ឬ ប្រើប្រាស់រួចហើយ) ដែលអ្នកដំណើរម្នាក់អាចត្រូវការ ជាចាំបាច់សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន នៅក្នុងអំឡុងពេលនៃការធ្វើដំណើរ ទទួលខុសត្រូវក្នុងរាល់ព្រឹត្តិការណ៍នៃការធ្វើដំណើរ. ប៉ុន្តែមិនរាប់បញ្ចូលទំនិញនាំចូល-នាំចេញទាំងឡាយ សំរាប់គោលបំណងផ្នែកពាណិជ្ជកម្ម ។ ទ្រព្យសម្បត្តិទាំងអស់នេះរាប់បញ្ចូល ប៉ុន្តែមិនកំរិតទៅលើ :

- សំលៀកបំពាក់
- ប្រដាប់សំអាង
- អល័ង្ការផ្ទាល់ខ្លួន
- ម៉ាស៊ីនថតរូបភាព-ថតភាពយន្តនៅស្ទៀម ឬថតមានចលនា ជាមួយគ្នានឹង ចំនួនដុំហ្វីល ខ្សែអាត់ និងគ្រឿងបន្សំជាប់ជាមួយសមរម្យ
- មាស៊ីនបញ្ចាំងស្លាយ ឬភាពយន្តយួរដៃជាប់ខ្លួន និងគ្រឿងបន្សំជាប់ជាមួយ ជាមួយនឹងចំនួនស្លាយ ឬហ្វីលសមរម្យ
- កែវយិត-កែវឆ្លុះ-កែវពង្រីក
- ឧបករណ៍ភ្លេងអាចយួរដៃបាន
- ឧបករណ៍ផលិតសំឡេងយួរដៃបាន រាប់ទាំងម៉ាស៊ីនថតខ្សែអាត់ និងម៉ាស៊ីនចាក់ឌីស
- វិទ្យុទទួលសំឡេងយួរដៃ
- ទូរស័ព្ទតូច ឬ យួរដៃ
- ទូរទស្សន៍យួរដៃ
- អង្គលីលេខយួរដៃ
- ម៉ាស៊ីនកុំព្យូទ័រយួរដៃផ្ទាល់ខ្លួន និងគ្រឿងបន្សំ
- ម៉ាស៊ីនគិតលេខយួរដៃ
- រទេះ និងប្រដាប់ប្រដារលេងកំសាន្តរបស់កូនក្មេង
- រទេះសំរាប់ជនពិការ
- ឧបករណ៍កីឡា

ខ- ការនាំចូលដោយរួចពន្ធ

អ្នកដំណើរត្រូវបានគេអនុញ្ញាតផងដែរ ឱ្យនាំចូល ដោយរួចពន្ធ និងអាករផ្សេងៗ នូវសំភារៈទាំងឡាយក្នុងចំនួនដ៏សមរម្យ សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន មិនរាប់បញ្ចូលទំនិញសំរាប់គោលបំណងនានាខាងពាណិជ្ជកម្ម ដែលស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសភាគី(ម្ចាស់ផ្ទះ) ប៉ុន្តែមិនតិចជាង :

១- សំរាប់ប្រើប្រាស់ : បារី២០០ដើម ឬ ស៊ីហ្គា៥០ដើម ឬ ២៥០ក្រាម នៃថ្នាំជក់ ឬការរួមបញ្ចូលគ្នានៃផលិតផលទាំងនេះ ដែលមានទំងន់សរុបមិនលើសពី ២៥០ក្រាម និងស្រា ០១ លីត្រ ។

២- ទំនិញផ្សេងទៀត ដែលមិនមែនជាទំនិញពាណិជ្ជកម្ម ដែលមានតំលៃសរុបប្រមាណ ៧៥ SDR អែសដេអែរ ។

៣- រូបិយវត្ថុសំរាប់ការចំណាយក្នុងការរស់នៅ ប្រមាណ ១០០ SDR ក្នុងការស្នាក់នៅមួយថ្ងៃ ។

ចំនួន និងបរិមាណទឹកប្រាក់សរុប អាចត្រូវកំរិតថែមទៀត សំរាប់អ្នកដំណើរទាំងឡាយដែល :

ក- នៅក្រោមអាយុពិតប្រាកដ ។

ខ- ឆ្លងកាត់ព្រំដែនច្រើនលើក(ច្រើនជាងមួយលើកក្នុងរយៈពេល ២៤ម៉ោង) ។

មាត្រា ៥.- ការត្រួតពិនិត្យអនាម័យ នៃទ្រព្យសម្បត្តិប្រើប្រាស់ផ្ទាល់ខ្លួន

ទ្រព្យសម្បត្តិប្រើប្រាស់ផ្ទាល់ខ្លួននៃពលរដ្ឋធ្វើការឆ្លងកាត់ព្រំដែន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យអនាម័យ ដោយអនុលោមទៅនឹងបញ្ញត្តិចែងក្នុងមាត្រាទី៥ នៃកិច្ចព្រមព្រៀង ។

ផ្នែកទី ៣
វិធានការសំរបសំរួល

មាត្រា ៦.- វិធានការសំរបសំរួល

វិធានការសំរបសំរួល ត្រូវបានគេចែងក្នុង ឧបសម្ព័ន្ធ ទី ៤ នៃកិច្ចព្រមព្រៀង ។

ផ្នែកទី ៤
លក្ខខណ្ឌ នៃការដឹកជញ្ជូនអ្នកដំណើរ

មាត្រា ៧.- តំលៃដឹកជញ្ជូន

ក-សំរាប់សេវាកម្មមិនមានកំណត់ពេលវេលា តំលៃនៃការដឹកជញ្ជូន ត្រូវចំហជាសេរី ដែលកំណត់ដោយកំលាំងទីផ្សារសេរី ប៉ុន្តែជាកម្មវត្ថុ ឬស្ថិតនៅក្រោមព្រំដែននៃការប្រឆាំងនឹងជំនឿទុកចិត្ត ឬទំនុកចិត្ត ធ្វើយ៉ាងណា

ដូចជាចៀសវាងការកំណត់តំលៃខ្ពស់ពេក ឬទាបពេក។ល។ ភាគីចុះកិច្ចសន្យា និងប្រតិបត្តិករដឹកជញ្ជូនទាំងឡាយត្រូវទប់ទល់ប្រឆាំងនឹងវិធានការកិច្ចព្រមព្រៀង ឬការអនុវត្តទាំងឡាយ ដែលធ្វើឱ្យខូចខាតដល់ទំរង់ នៃការប្រកួតប្រជែងដោយសេរី និងស្មោះត្រង់ ដូចជាកាតែល (ការព្រមព្រៀង ឬឃុបឃិតគ្នារវាងផលិតករទំនិញដូចគ្នា ដើម្បីរក្សាតំលៃលក់ នៅខ្ពស់) ការរំលោភដោយមុខរបរផ្តាច់មុខ ការទំលាក់តំលៃទាបជាសំរាម និងការបំពេញខាតពីរដ្ឋ ។ ពួកគេត្រូវ បានគេបដិសេធនូវហេតុបច្ច័យ ឬលទ្ធផលណាមួយ ហើយចាត់ទុកជាមោឃៈ និងគ្មានតំលៃ ។ ភាគីចុះកិច្ចសន្យាត្រូវធានាថា ប្រតិបត្តិករដឹកជញ្ជូនរបស់គេទាំងឡាយ នឹងប្រតិបត្តិទៅតាមច្បាប់ ។

ខ-សំរាប់សេវាកម្មមានពេលកំណត់ភាគីចុះកិច្ចសន្យាដែលពាក់ព័ន្ធនឹងព្រមព្រៀងគ្នានៅលើតំលៃនៃការដឹកជញ្ជូន ។

មាត្រា ៨.- ការអនុញ្ញាតឥវ៉ាន់ឬភារៈវត្ថុយកជាប់តាមខ្លួន និងការបង់ថ្លៃសំរាប់ឥវ៉ាន់ឬភារៈវត្ថុដែលលើស

ក- សំរាប់សេវាកម្មដឹកជញ្ជូនមិនមានកំណត់ពេលវេលា ការអនុញ្ញាតឥវ៉ាន់ ឬភារៈវត្ថុត្រូវទុកសំរាប់ការព្រមព្រៀងគ្នា ទៅវិញទៅមករវាងភាគីទាំងឡាយនៅក្នុងកិច្ចសន្យាដឹកជញ្ជូន ។

ខ- សំរាប់សេវាកម្មដឹកជញ្ជូនដែលមានកំណត់ពេលវេលា អ្នកដំណើរម្នាក់ៗត្រូវបានគេអនុញ្ញាតឱ្យយកតាមខ្លួនដោយមិនមានបង់ថ្លៃនូវឥវ៉ាន់ ឬភារៈវត្ថុរហូតដល់ ២០គីឡូក្រាមនិងមានទំហំសមរម្យអាចទទួលយកបាន ។ ប្រតិបត្តិករដឹកជញ្ជូនទាំងឡាយ អាចយកថ្លៃសំរាប់ឥវ៉ាន់ ឬភារៈវត្ថុដែលលើស ។ ការយកថ្លៃបន្ថែមអាចខុសៗគ្នាដោយទាក់ទងទៅនឹងផ្លូវដឹកជញ្ជូនប៉ុន្តែមិនត្រូវលើសពីប្រាំភាគរយនៃតំលៃសំបុត្រពេញលេញ សំរាប់អ្នកដំណើរក្នុងទំងន់ដែលលើសចំនួនមួយគីឡូក្រាម ។

មាត្រា ៩.- ឥវ៉ាន់ ឬភារៈវត្ថុមិនយកជាប់តាមខ្លួន

តំលៃសំរាប់ឥវ៉ាន់ ឬភារៈវត្ថុមិនយកជាប់តាមខ្លួននឹងត្រូវបានណែនាំឱ្យអនុវត្តទៅតាមរបប ដែលមានចែងក្នុងឧបសម្ព័ន្ធ ១០ នៃកិច្ចព្រមព្រៀង ។

ផ្នែកទី ៥

របបទទួលខុសត្រូវធានារ៉ាប់រងនៃអ្នកដឹកជញ្ជូន លើអ្នកដំណើរតាមផ្លូវគោក

មាត្រា ១០.- វិសាលភាពនៃការអនុវត្តន៍

ក- របបទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន ដែលដាក់ចេញខាងក្រោម ត្រូវអនុវត្តទៅលើគ្រប់កិច្ចសន្យា សំរាប់ការដឹកជញ្ជូនអ្នកដំណើរទាំងឡាយ និងឥវ៉ាន់ ឬភារៈវត្ថុរបស់ពួកគេសំរាប់ជារង្វាន់ (ទទួលកំរៃ) ឬមិនយក

ថ្លៃនៅក្នុងក្របខ័ណ្ឌពាណិជ្ជកម្មរបស់អ្នកដឹកជញ្ជូនដោយយានយន្តតាមផ្លូវថ្នល់ នៅពេលដែលទីកន្លែងចេញដំណើរ និងចំណុចគោលដៅរបស់អ្នកដំណើរ បានស្ថិតនៅក្នុងទឹកដីនៃភាគីចុះកិច្ចសន្យាផ្សេងទៀត ។

ខ- ការទទួលខុសត្រូវនៃអ្នកដឹកជញ្ជូន សំរាប់ការដឹកជញ្ជូនឥវ៉ាន់ ឬភារៈវត្ថុមិនយកជាប់តាមខ្លួននឹងត្រូវអនុវត្តទៅតាមរបបដែលមានចែងក្នុង ឧបសម្ព័ន្ធ១០ នៃកិច្ចព្រមព្រៀង ។

មាត្រា ១១.- កិច្ចសន្យានៃការដឹកជញ្ជូន

ក- ឯកសារដឹកជញ្ជូន

សំបុត្រអ្នកដំណើរ

១- កិច្ចសន្យានៃការដឹកជញ្ជូន ត្រូវបានគេកត់ត្រាឡើង តាមរយៈការចេញសំបុត្រអ្នកដំណើរជាឯកជន ឬជាការចូលរួមគ្នាមួយ ។ អវត្តមាន ភាពមិនត្រឹមត្រូវ មិនប្រក្រតី ឬការបាត់បង់សំបុត្រអ្នកដំណើរ មិនមានឥទ្ធិពលទៅលើអត្ថិភាព ឬសុពលភាពនៃកិច្ចសន្យានៃការដឹកជញ្ជូនឡើយ ដែលនៅតែជាកម្មវត្ថុនៅក្នុងមាត្រា និងបទប្បញ្ញត្តិ នៃឧបសម្ព័ន្ធនេះ ។

២- សំបុត្រអ្នកដំណើរត្រូវសរសេរជាភាសាជាតិ និងមានភាសាអង់គ្លេសអមទៅតាមចំណុចពិសេសខាងក្រោម :

- ឈ្មោះ និងអស័យដ្ឋាន នៃអ្នកដឹកជញ្ជូន
- ចំនុចនៃការចេញដំណើរ និងចំណុចគោលដៅ
- កាលបរិច្ឆេទនៃការធ្វើដំណើរ ឬរយៈពេលសុពលភាពនៃសំបុត្រអ្នកដំណើរ
- តំលៃនៃការធ្វើដំណើរ
- លក្ខខ័ណ្ឌយោងមួយដែលជាប្បញ្ញត្តិច្បាប់ និងស្របទៅនិតិវិធីទទួលខុសត្រូវ នៃឧបសម្ព័ន្ធនេះ

៣- សំបុត្រធ្វើដំណើរ អាចត្រូវបានគេចេញឱ្យទៅជនណាម្នាក់ដែលមានឈ្មោះ ឬឱ្យទៅអ្នកកាន់សំបុត្រនោះ ។

សំបុត្រចុះបញ្ជីឥវ៉ាន់ ឬភារៈវត្ថុ

១- សំរាប់ឥវ៉ាន់ ឬភារៈវត្ថុដែលមានចុះបញ្ជី អ្នកដឹកជញ្ជូនត្រូវចេញសំបុត្របង្កាន់ដៃចុះបញ្ជីឥវ៉ាន់ ឬភារៈវត្ថុ ដែលអាចដាក់បញ្ចូលគ្នា ឬភ្ជាប់គ្នាទៅនឹងសំបុត្រធ្វើដំណើរ ។

២- សំបុត្រឥវ៉ាន់ ឬភារៈវត្ថុ ត្រូវសរសេរជាភាសាជាតិ និងភាក្សាអង់គ្លេសនៅលើចំណុចទាំងឡាយដូចខាងក្រោម:

- ឈ្មោះ និងអស័យដ្ឋាន នៃអ្នកដឹកជញ្ជូន
- ចំនុចនៃការចេញដំណើរ និងចំណុចគោលដៅ
- កាលបរិច្ឆេទ នៃការចេញ
- តំលៃនៃការធ្វើដំណើរ

- លក្ខខ័ណ្ឌយោងមួយ សំរាប់ជាបញ្ញត្តិច្បាប់ ដែលមាន របបបទទួលខុសត្រូវនៃឧបសំព័ន្ធនេះ
- ចំនួន និងទំងន់នៃឥវ៉ាន់ ឬភារៈវត្ថុ

៣- ក្នុងករណីអវត្តមានសំបុត្រចុះបញ្ជីឥវ៉ាន់(ភារៈវត្ថុ) ឬការការភ្លេចភ្លាំង ក្នុងការបញ្ជាក់ទំងន់ ឬចំនួនដែលត្រូវបានគេសន្មត់ថា ជាការអនុញ្ញាតអតិបរមា ។

ខ- ការកត់សំគាល់

១- ក្នុងពេលចុះបញ្ជីឥវ៉ាន់ ឬភារៈវត្ថុ អ្នកដឹកជញ្ជូនត្រូវត្រួតពិនិត្យស្ថានភាពជាក់ស្តែងរបស់វា និងនៅពេលចាំបាច់ត្រូវធ្វើការកត់សំគាល់សមរម្យ នៅលើសំបុត្រឥវ៉ាន់ (សំបុត្រចុះបញ្ជីឥវ៉ាន់) ។

២- ក្នុងពេលអវត្តមានការកត់សំគាល់នៅលើឥវ៉ាន់ពីអ្នកដឹកជញ្ជូនឥវ៉ាន់ ឬភារៈវត្ថុនោះ ត្រូវសន្មត់ថា ស្ថិតនៅក្នុងស្ថានភាពល្អប្រសើរ ។

មាត្រា ១២.- គោលការណ៍ទាំងឡាយ សំរាប់ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន

ក- អណ្តិច្បាប់

ប្បញ្ញត្តិណាមួយនៃកិច្ចសន្យាដឹកជញ្ជូន ដែលធ្វើបដិញ្ញត្តិកម្ម (ផ្ទុយអំពី) ដោយផ្ទាល់ ឬដោយប្រយោលចេញ អំពីមាត្រា ស្តីពីរបបទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន នៃឧបសំព័ន្ធនេះត្រូវបានប្រកាសបដិសេធ និងទុកជាមោឃៈ លើកលែងតែមានការយល់ព្រម ឬពេញចិត្តអំពីអ្នកដំណើរ ។ ប៉ុន្តែការប្រកាសបដិសេធ និងការទុកជាមោឃៈ នៃមាត្រ ឬប្បញ្ញត្តិនោះ ទោះជាយ៉ាងណាក៏ដោយ ក៏មិនមានឥទ្ធិពលទៅដល់សុពលភាពនៃមាត្រា ឬប្បញ្ញត្តិដ៏ទៃទៀតនៃកិច្ចសន្យាទេ ។

ខ- ក្នុងកិច្ចសន្យា និងកំហុសរដ្ឋប្បវេណី (កំហុសស៊ីវិល)

និតិវិធីធានារ៉ាប់រងបច្ចុប្បន្ន ត្រូវនាំមុខការប្តឹងតវ៉ាណាមួយដែលកើតឡើង នៅក្រៅពីសកម្មភាព នៃកិច្ចសន្យាដឹកជញ្ជូននៅក្រោមឧបសំព័ន្ធនេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយវាត្រូវបានគេចែងទាំងនៅក្នុងកិច្ចសន្យា ឬកិច្ចសន្យាបន្ថែមផ្សេងទៀត ។

គ- ការទទួលខុសត្រូវជំនួសដោយ អ្នកបំរើសេវ៉ា, ភ្នាក់ងារ និងអ្នកចុះកិច្ចសន្យាបន្ត (អ្នកម៉ៅការបន្ត)

ភ្ជាប់មកជាមួយនឹងសកម្មភាពការងារទាំងឡាយរបស់គេ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវសំរាប់សកម្មភាព និង/ឬអសកម្មភាព (ការមិនបានធ្វើ) របស់អ្នកបំរើសេវ៉ាភ្នាក់ងារ និងអ្នកចុះកិច្ចសន្យាបន្ត (ម៉ៅការបន្ត) របស់គាត់ ជាអ្នកដែលគាត់នឹងត្រូវផ្តល់សិទ្ធិអោយពួកគេប្រើប្រាស់កិច្ចការពារដូចគ្នាទៅនឹងអ្នកដឹកជញ្ជូនដែរ ។

មាត្រា ១៣.- កម្មវត្ថុនៃការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន

ក- ការរងរបួសលើរាងកាយបុគ្គល

អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវ សំរាប់ការបាត់បង់ ឬខូចខាតដែលជាលទ្ធផលបណ្តាលឱ្យមានការស្លាប់ ឬរងរបួសលើរាងកាយ ឬស្មារតីទៅលើអ្នកដំណើរណាម្នាក់ ដែលហេតុផលមកពីលទ្ធផល នៃគ្រោះថ្នាក់ដែលពាក់ព័ន្ធទៅនឹងការដឹកជញ្ជូន និងកើតឡើងនៅពេលអ្នកដំណើរកំពុងជិះនៅលើរថយន្ត ឬនៅពេលឡើង និងពេលចុះពីរថយន្ត ។

ខ- ការយឺតយ៉ាវ

អ្នកដឹកជញ្ជូន ត្រូវផ្តល់ការទទួលខុសត្រូវ សំរាប់ការខូចខាត ដែលជាលទ្ធផលនៃការយឺតយ៉ាវក្នុងដំណើរមកដល់នៃអ្នកដំណើរ និង/ឬភារៈវត្ថុរបស់គេ ។

គ- ការបាត់បង់ ឬខូចខាតឥវ៉ាន់ ឬភារៈវត្ថុចុះបញ្ជី (ឥវ៉ាន់ផ្ញើតាមខ្លួនចុះបញ្ជី)

១- អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវ សំរាប់ការខូចខាតទាំងស្រុង ឬមួយផ្នែកចំពោះភារៈវត្ថុ ដែលកើតឡើងនៅក្នុងអំឡុងពេលចាប់ពីពេលដែលអ្នកដឹកជញ្ជូនទទួលខុសត្រូវផ្ទុកទំនិញ និងពេលចែកចាយទំនិញ ។

២- ការបាត់បង់ដោយការសន្និដ្ឋាន Constructive Loss

ប្រសិនបើភារៈវត្ថុចុះបញ្ជីផ្ញើតាមខ្លួន មិនត្រូវបានគេផ្តល់ ឬចែកចាយក្នុងរយៈពេល៣០ថ្ងៃក្រោយពេលវេលាច្បាស់លាស់ដែលបានកំណត់ ឬពេលវេលាទៅដល់ធម្មតា ហើយដែលពេលបន្ទាប់មកនៅតែមិនឃើញទៅដល់ វត្ថុបញ្ញើតាមខ្លួន(ឬភារៈវត្ថុ)នោះ ត្រូវបានចាត់ទុកថាបាត់បង់ ។ ពេលនោះអ្នកដំណើរមានសិទ្ធិប្តឹងទារសងសំណងសំរាប់ការបាត់បង់នោះ ។ នៅពេលគេបានរកឃើញភារៈវត្ថុ (ឬវត្ថុបញ្ញើ) នោះ នៅពេលក្រោយបន្ទាប់មកទៀត អ្នកដឹកជញ្ជូនត្រូវធ្វើការជូនដំណឹងជាបន្ទាន់ទៅអ្នកដំណើរ ដែលគេត្រូវមានសិទ្ធិជ្រើសរើសក្នុងការ ទទួលយកនូវការចែកចាយភារៈវត្ថុ ជំនួសឱ្យការផ្តល់មូលនិធិសំរាប់ជាសំណង ដែលបានទទួលរួចហើយ ប៉ុន្តែដោយមិនមានជំទាស់ទៅលើការប្តឹងតវ៉ាសំរាប់សំណង លើការបាត់បង់ខូចខាតជាផ្នែក១ទេ ។ ប្រសិនបើអ្នកដំណើរមិនទាមទារយកត្រឡប់មកវិញនូវឥវ៉ាន់បញ្ញើ ឬភារៈវត្ថុទេនោះ អ្នកដឹកជញ្ជូនត្រូវបានទទួលសិទ្ធិចាត់ចែងលើវត្ថុបញ្ញើ ឬភារៈវត្ថុទាំងនោះទៅតាមការសំរេចចិត្តរបស់ខ្លួន នៅក្រោមច្បាប់ នៃទីកន្លែងដែលទំនិញទាំងនោះបានស្ថិតនៅ ។

ឃ- ការបាត់បង់ ឬការខូចខាត ឥវ៉ាន់ ឬភារៈវត្ថុយួរដៃ វត្ថុប្រើប្រាស់ផ្ទាល់ខ្លួន

អ្នកដឹកជញ្ជូនត្រូវផ្តល់ការទទួលខុសត្រូវសំរាប់ការបាត់បង់ ឬការខូចខាតទាំងស្រុង ឬដោយផ្នែកទៅលើវត្ថុប្រើប្រាស់ផ្ទាល់ខ្លួន ដែលអ្នកដំណើរបានយក ឬពាក់ជាប់តាមខ្លួន នៅពេលមានគ្រោះថ្នាក់មួយ ដែលពាក់ព័ន្ធក្នុងការដឹកជញ្ជូន និងកើតឡើងនៅពេលអ្នកដំណើរកំពុងស្ថិតនៅលើយានយន្ត ឬនៅពេលឡើងឬចុះពីរថយន្ត ។

មាត្រា ១៤.- ទំហំនៃការសំណង និងព្រំដែននៃការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន

ក- លក្ខណៈទូទៅ

១- ព្រំដែននៃការទទួលខុសត្រូវ មិនត្រូវរាប់បញ្ចូលការចំណាយខាងច្បាប់ និងការប្រាក់ទេ ។ ព្រំដែនកំណត់ដែលខ្ពស់បំផុតអាចត្រូវគេព្រមព្រៀងគ្នា រវាងគូរភាគីទៅតាមកិច្ចសន្យានៃការដឹកជញ្ជូន ។

២- បន្ថែមទៅលើសំណង ក្រុមហ៊ុនដឹកជញ្ជូនត្រូវសងត្រលប់មកវិញនូវតំលៃដឹកជញ្ជូនពេញលេញទាំងស្រុង ឬមួយចំណែក ដោយសមាមាត្រទៅនឹងកំរិតនៃកំហុសរបស់គេ ។ គេនឹងមិនមានជាប់ជំពាក់ក្នុងការខូចខាតនាពេលខាងមុខទៀតទេ ។

៣- ទំហំនៃការបង់ថ្លៃជាសំណងសំរាប់ការស្លាប់ របួស ឬការរងរបួសខាងរាងកាយ និងស្មារតី នៃអ្នកដំណើរ និងសំរាប់ការខូចខាត ឬក៏ការបាត់បង់ទាំងស្រុង ឬការបាត់បង់ដោយចំណែករបស់ឥវ៉ាន់បញ្ញើ(ភារៈវត្ថុ) ឬការខូចខាតដែលបង្កើតឡើង អំពីការយឺតយ៉ាវត្រូវបង្កើតឡើង ដោយអនុលោមទៅតាមច្បាប់តុលាការរបស់ជាតិ ដែលសកម្មភាពទទួលខុសត្រូវបានប្រព្រឹត្តឡើងនៅទីនោះ ។

៤- សិទ្ធិប្តឹងផ្តល់របស់អ្នកប្តឹងតវ៉ា ត្រូវកំណត់ផងដែរ ដោយអនុលោមទៅតាមច្បាប់តុលាការរបស់ជាតិ ដែលសកម្មភាពទទួលខុសត្រូវបានប្រព្រឹត្តឡើងនៅទីនោះ ។

៥- អ្នកប្តឹងតវ៉ាមានសិទ្ធប្តឹងយកការប្រាក់ ទៅលើប្រាក់សំណង នៅក្នុងអត្រាការប្រាក់ 5% ក្នុង១ឆ្នាំ ចាប់ពីថ្ងៃដែលពាក្យបណ្តឹងបានត្រូវគេធ្វើជាលាយលក្ខ័អក្សរ ឬនីតិវិធីច្បាប់ត្រូវបានរៀបចំឡើងនៅតុលាការ ឬសវនាការ តាមអាជ្ញាកណ្តាលត្រូវបានគេផ្តួចផ្តើមធ្វើឡើង ។

ខ- ទាក់ទងដល់ការរងរបួសដល់ខ្លួនប្រាណបុគ្គល

១- ការបង់ថ្លៃជាសំណងសរុប ដែលធ្វើឡើងដោយអ្នកដឹកជញ្ជូន សំរាប់ការស្លាប់ ឬការរងរបួសដល់រាងកាយ ឬខាងស្មារតីទៅលើអ្នកដំណើរម្នាក់ ដោយគោរពទៅតាមស្ថានភាពកើតឡើងដូចៗគ្នា ទោះជាយ៉ាងណាក៏ដោយមិនត្រូវអោយលើសពី 9.000 SDR សំរាប់អ្នករងគ្រោះម្នាក់ៗ ។

២- ប្រសិនបើមានបណ្តឹងតវ៉ាច្រើនជាងមួយ សំរាប់អ្នករងគ្រោះម្នាក់ ហើយប្រសិនបើបរិមាណសរុប នៃពាក្យបណ្តឹងរបស់គេ លើសពីព្រំដែនដែលកំណត់ឡើង ពាក្យបណ្តឹងទាំងនោះត្រូវបានគេកាត់បន្ថយអោយសមាមាត្រគ្នា ។

គ- ទាក់ទងដល់ការការបាត់បង់ និងការខូចខាត ឥវ៉ាន់ផ្ញើតាមខ្លួន(ភារៈវត្ថុ)

១- ឥវ៉ាន់បញ្ញើ ឬភារៈវត្ថុចុះបញ្ជី :

ទំហំសំណងបានមកពីអ្នកដឹកជញ្ជូន សំរាប់ការបាត់បង់ ឬខូចខាតទៅលើឥវ៉ាន់បញ្ញើ ឬភារៈវត្ថុចុះបញ្ជី មិនត្រូវលើសពី 8.33 SDR ក្នុងទំងន់សរុបសុទ្ធសាធមួយគីឡូក្រាម នៃភារៈវត្ថុដែលផ្ញើជាក់ស្តែង ឬតាមរាល់មុខទំនិញដែលខូចខាត ឬស្មើនឹង 166.67 SDR សំរាប់មួយឯកតា ដែលជាសំណងខ្ពស់បំផុត ។

២- ឥវ៉ាន់ ឬភារៈវត្ថុយួរជាប់ដៃ និងវត្ថុប្រើប្រាស់ផ្ទាល់ខ្លួនៈ

ទំហំសំណងបានមកពីអ្នកដឹកជញ្ជូន សំរាប់ការបាត់បង់ ឬខូចខាត ទៅលើទ្រព្យសម្បត្តិ ឬភារៈវត្ថុ យួរជាប់ដៃ ឬវត្ថុប្រើប្រាស់ផ្ទាល់ខ្លួន ដែលពាក់ជាប់នឹងខ្លួន ឬកាន់ជាប់នឹងដៃ ដោយអ្នកដំណើរម្នាក់ ត្រូវកំណត់ចំនួនត្រឹមតែ 166.67 SDR តែប៉ុណ្ណោះ ។

៣- ព្រំដែនសរុប :

ទំហំសំណងសរុបបានមកពីការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន សំរាប់ទ្រព្យសម្បត្តិ ឬភារៈវត្ថុរបស់អ្នកដំណើរម្នាក់ ត្រូវបានគេកំណត់មិនឱ្យលើសពី 666.67 SDR ទេ ។

ឃ- ការយឺតយ៉ាវ

ទំហំសំណងបានមកពីអ្នកដឹកជញ្ជូន សំរាប់ការខូចខាតផ្សេងទៀត ក្រៅអំពីការខូចខាតខាងរូបវ័ន្តទៅលើឥវ៉ាន់ ឬការរង របួសដល់រាងកាយដែលជាលទ្ធផលបានមកពីការយឺតយ៉ាវ ត្រូវបានគេកំណត់ក្នុងចំនួនមួយ មិនឱ្យលើសពីតំលៃដឹកជញ្ជូន ។

មាត្រា ១៥.- ការមិនរាប់បញ្ចូលក្នុងការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន

ក- អ្នកដឹកជញ្ជូនត្រូវបានរំដោះផុតពីការទទួលខុសត្រូវ ទៅក្នុងករណីដែលគ្រោះថ្នាក់ ការបាត់បង់ ការយឺតយ៉ាវ និងខូចខាត កើតឡើងដោយ :

១- ករណីប្រធានស័ក្តិ ។

២- កំហុស ឬឥទ្ធិពលផ្ទៃក្នុងរបស់ឥវ៉ាន់ ឬភារៈវត្ថុ ឬរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ។

៣- ការខ្វះចន្លោះ ឬចេញពីកំហុស ដោយការមិន យកចិត្តទុកដាក់របស់អ្នកដំណើរដោយផ្ទាល់

៤- ស្ថានភាពសុខភាពបុរេនិច្ឆ័យរបស់អ្នកដំណើរ

ខ- ស្ថានភាពខ្វះចន្លោះនៃយានយន្តដែលប្រើប្រាស់សំរាប់សកម្មភាពនៃការដឹកជញ្ជូន ឬកំហុសជារូបវ័ន្ត ឬជាស្មារតី នៃអ្នក

បើកបរ មិនត្រូវបានគេរំដោះ ឬបន្ធូបន្ថយចេញពីការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនបានឡើយ ។

មាត្រា ១៦.- ការលើកលែង នូវការមិនរាប់បញ្ចូលក្នុងការទទួលខុសត្រូវ ឬព្រំដែននៃការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន

អ្នកដឹកជញ្ជូនមិនមានសិទ្ធិ ទទួលប្រយោជន៍អំពីការកំណត់ព្រំដែន ឬការលើកលែងមិនរាប់បញ្ចូល នៃការ ទទួលខុសត្រូវ ប្រសិនបើមានភ័ស្តុតាងអំពីការស្លាប់ ការរងរបួស ការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវក្នុងការចែកចាយ និង/ឬការទៅដល់ ដែលបណ្តាលមកពីការធ្វើសកម្មភាព ឬការមិនធ្វើសកម្មភាពផ្ទាល់ខ្លួនណាមួយ របស់ក្រុមហ៊ុនខ្លួន ឬភ្នាក់ងាររបស់ខ្លួន និងអ្នកចុះកិច្ចសន្យាបន្ត ដែលបានធ្វើឡើងដោយចេតនា បណ្តាលឱ្យមានការស្លាប់ ការរងរបួស ការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសជាទូទៅ ហើយដែលដឹងថា ការស្លាប់ ការរងរបួស ការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវពិតជាកើតឡើង ។

មាត្រា ១៧.- ការប្តឹងតវ៉ា និងបណ្តឹង

ក- ការកត់សំគាល់ក្នុងពេលចែកចាយឥវ៉ាន់បញ្ញើ ឬភារះវត្ថុ

១- នៅពេលទទួលឥវ៉ាន់បញ្ញើ ឬភារះវត្ថុ អ្នកធ្វើដំណើរត្រូវតែកពិនិត្យចំនួនមុខទំនិញ និងស្ថានភាពនៃឥវ៉ាន់បញ្ញើ ឬភារះវត្ថុ និងប្រសិនបើមានការខ្វះចំនួន ឬខូចខាត ត្រូវធ្វើពាក្យបណ្តឹងតវ៉ាដ៏សមរម្យជាបន្ទាន់ និងជាលាយល័ក្ខអក្សរទៅក្រុមហ៊ុនដឹកជញ្ជូន ។

២- នៅក្នុងករណីដែលការទទួលទំនិញមិនមានកំណត់សំគាល់ វត្ថុបញ្ញើ ឬភារះវត្ថុត្រូវសន្មត់ថា បានចែកចាយជាសំរេចសព្វគ្រប់ និងដោយគ្មានខូចខាតសោហ្មង ។

ខ- ការកំណត់ព្រំដែនពេលវេលា

ពាក្យបណ្តឹងតវ៉ាទាំងឡាយសំរាប់ទាមទារជាសំណង ពីអ្នកដឹកជញ្ជូនម្នាក់នៅក្រោមឧបសម្ព័ន្ធនេះត្រូវកំណត់ព្រំដែនពេលវេលា លើកលែងតែបណ្តឹងណាមួយត្រូវបានគេបំពេញរួចហើយនៅឯតុលាការ ឬការសំរេច ដោយអជ្ញាកណ្តាល ត្រូវបានធ្វើឡើងនៅក្នុងរយៈពេលកំណត់បន្ទាប់មក ក្រោយពីថ្ងៃដែលមានគ្រោះថ្នាក់ ឬតាមពេលវេលាជាក់ស្តែង ឬពេលវេលាធម្មតា ពេលទៅដល់ចំណុចគោលដៅ ពេលវេលាណាមួយក៏បាន ដែលស្ថិតនៅក្រោយគេបំផុត :

១- រយៈពេលពាឆ្នាំក្នុងករណីស្លាប់ ឬរងរបួស ឬរបួសផ្សេងទៀតខាងផ្នែករាងកាយ និងស្មារតីទៅលើអ្នកដំណើរម្នាក់

២- ប្រាំមួយខែ ក្នុងករណីបាត់បង់ ឬខូចខាត និងយឺតយ៉ាវ ដល់ឥវ៉ាន់បញ្ញើ ឬភារះវត្ថុ និងវត្ថុប្រើប្រាស់ផ្ទាល់ខ្លួនទាំងឡាយ និងការយឺតយ៉ាវក្នុងការមកដល់នៃអ្នកដំណើរ ។

គ- យុត្តាធិការ(សាលាកាត់ក្តី)

១- បណ្តឹងណាមួយ សំរាប់ទាមទារជាសំណង ដែលផ្អែកលើឧបសម្ព័ន្ធនេះ អាចដាក់ទៅកាន់តុលាការ នៃភាគីចុះកិច្ចសន្យា :

- នៅទីកន្លែងណាដែលក្រុមហ៊ុនដឹកជញ្ជូនបានចាប់ផ្តើមចេញដំណើរ ឬបានទៅដល់ចំណុចគោលដៅ
- នៅទីកន្លែងណាដែលការបាត់បង់ ឬការខូចខាត បានកើតឡើង ប្រសិនបើមានទីតាំងច្បាស់លាស់
- នៅទីកន្លែងណាដែលជាកន្លែងមូលដ្ឋាន សំរាប់កិច្ចការជំនួញនៃអ្នកដឹកជញ្ជូនដែលបានស្ថិតនៅ
- នៅទីកន្លែងណាដែលជាលំនៅដ្ឋានរស់នៅរបស់អ្នកប្តឹងតវ៉ាបានស្ថិតនៅ ។

២- អ្នកប្តឹងតវ៉ា សំរាប់ទាមទារជាសំណង អាចផ្សះផ្សារគ្នាផងដែរ តាមរយៈការសំរេចពីអជ្ញាកណ្តាល ដោយផ្អែកលើមូលដ្ឋាននៃការព្រមព្រៀងគ្នាមួយរវាងភាគីពាក់ព័ន្ធ បន្ទាប់ពីពាក្យបណ្តឹងតវ៉ាត្រូវបានធ្វើឡើង ។

មាត្រា ១៨.- កាតព្វកិច្ចធានារ៉ាប់រងទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនចំពោះអ្នកដំណើរ

ដោយគោរពទៅតាមការទទួលខុសត្រូវរបស់គេ សំរាប់ការស្លាប់ ឬរងរបួសនៃអ្នកដំណើរទាំងឡាយ អ្នកដឹកជញ្ជូនត្រូវប្រតិបត្តិទៅតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមមាត្រា៦(ស) នៃឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងដោយធ្វើកិច្ចសន្យាសំរាប់ ទទួលខុសត្រូវលើអ្នកដំណើរ នូវការធានារ៉ាប់រង ដោយការរងរបួសនៃរាងកាយ សំរាប់ការខូចខាតជាក់ស្តែង រហូតដល់ទៅ 9,000 SDR ដោយមិនមានការដាក់ជំនួសដោយអ្នកផ្សេងទៀត និង/ឬ ដោយការបោះបង់ចោលនូវឧបាស្រ័យ (សិទ្ធិទាមទារ និងទទួលមកវិញនូវអ្វីដែលបានបាត់បង់) ។

ផ្នែកទី ៦

អវសានប្បញ្ញត្តិ

មាត្រា ១៩.- ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើសុំធ្វើវិសោធនកម្មលើឧបសម្ព័ន្ធតាមរយៈគណកម្មាធិការរួម ។ ដែលការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆ័ន្ទ ពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

មាត្រា ២០.- ការផ្តល់សច្ចាប័ន និងការយល់ព្រម

ក-ឧបសម្ព័ន្ធនេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រមនៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា ។ ការអនុវត្តដូចគ្នានេះ ត្រូវបានគេយកមកប្រើនៅក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធប្រសិនបើមាន ។

ខ-ផ្នែកទី១ (បទប្បញ្ញត្តិទូទៅ) ផ្នែកទី ២: ការត្រួតពិនិត្យអន្តោប្រវេសន៍(ការចូល/ការចេញ)សុខភាព និងគយ

រដ្ឋាករ ។ ផ្នែកទី ៣ : វិធានការ សំរបសំរួល និងផ្នែកទី ៤: លក្ខខ័ណ្ឌ នៃការដឹកជញ្ជូនអ្នកដំណើរ នៃឧបសម្ព័ន្ធនេះ អាចផ្ដល់សច្ចាប័ន ឬការយល់ព្រមចូលដាច់ដោយឡែកពីគ្នាចេញអំពីផ្នែកទី ៥: របបទទួលខុសត្រូវធានារ៉ាប់រង នៃអ្នកដឹកជញ្ជូនចំពោះអ្នកដំណើរតាមផ្លូវគោក) ។

មាត្រា ២១.- ការចូលជាធរមាន

ក- ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្ដល់សច្ចាប័ន ឬការយល់ព្រមចូលនឹងត្រូវមានប្រសិទ្ធិភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យាដែលបានផ្ដល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធ ។ ការអនុវត្តដូចគ្នានេះត្រូវបានគេយកមកប្រើក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន ។

ខ- ក្នុងករណីដែលសច្ចាប័ន /ការយល់ព្រមចូល ដាច់ដោយឡែកពីគ្នា លើផ្នែកទី១ (បទប្បញ្ញត្តិទូទៅ) ផ្នែកទី ២: ការត្រួតពិនិត្យអន្តោប្រវេសន៍ (ការចូល/ការចេញ) សុខភាព និងគយរដ្ឋាករផ្នែកទី ៣: វិធានការសំរបសំរួល និង ផ្នែកទី ៤: លក្ខខ័ណ្ឌនៃការដឹកជញ្ជូនអ្នកដំណើរនៃឧបសម្ព័ន្ធនេះអាចចូលជាធរមានដាច់ដោយឡែកពីគ្នាចេញអំពីផ្នែកទី ៥ : របបទទួលខុសត្រូវធានារ៉ាប់រងនៃអ្នកដឹកជញ្ជូនចំពោះអ្នកដំណើរតាមផ្លូវគោក ។

មាត្រា ២២.- ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធឱ្យស្របទៅតាមខ្លឹមសារ នៃឧបសម្ព័ន្ធ ។

មាត្រា ២៣.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតឡើយ ។

មាត្រា ២៤.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានីមួយៗអាចព្យួរទុកជាបណ្ដោះអាសន្ន នូវការអនុវត្តឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែកដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការវឹកវរជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន ។ ភាគីចុះកិច្ចសន្យានឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀតភ្លាម តាមតែអាចធ្វើទៅបានអំពីការព្យួរទុក និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណាដែលសភាពការណ៍វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ ។

មាត្រា ២៥.- ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តគោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះ មិនអាចផ្ដាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះទេ ។ នៅក្នុងករណីដែលវិសមិតរវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ ។ នៅក្នុងករណីដែលវិសមិតរវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ

ឬពិធីសារផ្សេងទៀត នោះវិសិមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នានឹងកិច្ចព្រមព្រៀង ។

មាត្រា ២៦.- ការដោះស្រាយជំលោះ

ជំលោះ ឬទំនាស់រវាងភាគី០២ ឬច្រើននៃភាគីចុះកិច្ចសន្យានៅលើការបកស្រាយ ឬការអនុវត្តឧបសម្ព័ន្ធ ត្រូវស្រុះស្រួលគ្នាលើកយកមកដោះស្រាយដោយផ្ទាល់ឬដោយការចរចារតាមគោលការណ៍សន្តិវិធីតាមរយៈគណៈកម្មាធិការរួម ។

មាត្រា ២៧.- ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាធរមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធដាច់ដោយឡែក ចេញអំពីកិច្ចព្រមព្រៀងបានទេ ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធិប្រទានពេញលេញពីអាជ្ញាធររៀងៗខ្លួន បានចុះហត្ថលេខា លើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ ទីក្រុងគុនមីង ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៥ ជា ០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា

តំណាងរាជរដ្ឋាភិបាលកម្ពុជា

ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម **ឈាង ជុនស៊ាន** រដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ឯកឧត្តម **សំពោង មន្តស់ទីឡៃ** រដ្ឋមន្ត្រីប្រៃសណីយ៍ ទូរគមនាគមន៍ ដឹកជញ្ជូន និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា

ឯកឧត្តម **ស៊ូ ទាំ** រដ្ឋមន្ត្រីអភិវឌ្ឍន៍ជែនការ និងសង្គមកិច្ច

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍

ឯកឧត្តម **ស៊ូរីយ៉ា រុងហ្វ៉ឹងគីត** រដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ឯកឧត្តម **ងាំ ទេមិញ** អនុរដ្ឋមន្ត្រីដឹកជញ្ជូន

ANNEX 5: CROSS-BORDER MOVEMENT OF PEOPLE

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed at Vientiane on 26 November 1999, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China at Phnom Penh on 3 November 2002, and acceded to by the Union of Myanmar at Dali City on 19 September 2003, and amended at Phnom Penh on 30 April 2004 (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Articles 5 and 6 of the Agreement, calling for this Annex to provide technical details,

HAVE AGREED AS FOLLOWS:

Part I: General Provisions

Article 1: Definitions

For the purpose of this Annex, the following meanings shall apply to the underlined terms:

(a) Accompanied Luggage: luggage that travels with the passenger on the same means of transportation.

(b) Carrier: a person who undertakes to carry for reward or gratuitously in the course of his/her business, a passenger and, where appropriate, the latter's luggage.

(c) Delay: delay in the performance of the carriage when it did not arrive at the destination within the agreed period or in the absence of such an agreement, within the normal period of time required for a due diligent carrier in the same circumstances.

(d) Force Majeure: circumstances resulting in injury, loss, damage, or delay that the carrier could not foresee and avoid, and the consequences of which the carrier was unable to prevent or control.

(e) Hand Luggage: luggage kept by the passenger with him/her during the carriage.

(f) Passenger: any person who, in the performance of a contract of carriage made by him/her or on his/her behalf, is carried by a carrier either for reward or gratuitously in the course of the latter's business.

(g) Registered Luggage: luggage taken over from the passenger by the carrier for the purpose of the carriage.

(h) Remarks: statements made by the carrier or the passenger on the condition of the luggage upon its taking over or delivery.

(i) Special Drawing Right (SDR): a unit of account defined by the International Monetary Fund (IMF) - conversion of sums into national currencies shall be calculated in accordance with the method of valuation applied by the IMF.

(j) Transport Operator: a natural or legal, private or public person, who carries goods and/or People by road for reward.

(k) Unaccompanied Luggage: luggage conveyed like cargo, normally not on the same means of transportation as the passenger.

Part II: Immigration (Entry/Exit), Health, and Customs Control

Article 2: Valid Travel Documents and Visas

(a) Passport or International Travel Document for People Crossing the Border

People crossing the border shall carry a valid passport or international travel document in lieu of passport. Each Contracting Party shall provide the other Contracting Parties with specimens of passports or international travel documents in lieu of passports through diplomatic channels. People crossing the border shall meet the visa requirements of the Host Country, unless exempted in accordance with bilateral or regional agreements or Host Country laws and regulations.

(b) Visa Issuance Conditions and Procedures

(i) General Conditions for People Crossing the Border

- Issuance formalities, conditions, procedures, types, and characteristics of visas shall be subject to laws and regulations of the Host Country, except as provided in this Annex.

- The time for issuance or refusal of a visa shall be no more than 10 working days.

(ii) Specific Conditions for Driver/Crew of Commercially Operated Road Vehicles (hereinafter referred to as crew/driver)

- Period of Visa Validity

The driver/crew shall be issued by the Host Country a multiple entry/exit visa for a minimum validity period of one year. Shorter durations of the validity period and lesser entry/exit frequency may be allowed upon request by the applicant.

- Required Documents To Support the Application

The application for a visa by a driver/crew member shall be supported by a certificate of employment issued by an authorized transport operator of the Home Country licensed in accordance with the requirements of Annex 9 to the Agreement. The applicant driver shall also submit a copy of his/her driving license issued in accordance with Annex 16 to the Agreement.

(c) Language

In addition to any national language(s), all particulars in passports or international travel documents in lieu of passports and visas shall also be expressed in English language.

Article 3: Health Inspection of People

(a) General: The Host Country shall apply its national laws and regulations in compliance with the International Health Regulations of the World Health Organization (WHO).

(b) Principle: no examination.

As a rule, people who:

(i) carry the prescribed WHO health documents;
(ii) do not come from and have not passed through a known infected or risk area; and
(iii) do not show any external symptoms of a contagious disease endangering public health

will not be subjected to routine medical checks, inspection, or examination.

(c) Exception: examination is permissible in particular cases.

People who may be subjected to medical examination are those who:

(i) do not carry the prescribed WHO health documents;
(ii) come from or have transited through a known infected or risk area; or
(iii) show external symptoms of a contagious disease endangering public health.

(d) Reaction to Spotting Infected Individuals

Whenever people are, upon medical examination, found to be infected with a contagious disease endangering public health, the relevant competent authority:

(i) may deny access to the territory or repel foreign individuals if their health condition enables them to travel and advise them to return to their Home Country;
(ii) if their health condition does not enable them to travel, shall offer appropriate medical care and treatment in isolation/quarantine to the individuals; and
(iii) shall notify promptly the WHO via the appropriate channels in accordance with the applicable rules.

(e) Health Documents: People may be required to carry personal health documents prescribed by the WHO (e.g., yellow fever vaccination certificate).

Article 4: Customs Control of Personal Effects: Duty-Free Allowance

(a) Temporary Admission

(i) Temporary importation of personal effects by non-resident private persons shall be exempt from customs duties and taxes in the Host Country, subject to re-exportation within the permissible period of stay and without having undergone any change apart from depreciation and/or consumption. Also, re-importation in the same state (without replacement of any part or accessory) by returning residents in their Home Country of personal effects they took along at the time of their departure from their Home Country shall be free of customs duties and taxes.

(ii) For the purpose of this provision, personal effects shall mean all articles (new or used) that a traveler may reasonably require for his/her personal use during the journey, taking into account all circumstances of the journey, but excluding any goods imported or exported for commercial purposes. They include but are not limited to:

- clothing;
- toilet articles;
- personal jewelry;
- still and motion picture cameras together with a reasonable supply of films, tapes, and accessories therefor;
- portable slide or film projectors and accessories therefore together with a reasonable quantity of slides or films;
- binoculars;

- portable musical instruments;
- portable sound reproduction devices including tape recorders and compact disc players;
- portable radio receivers;
- cellular or mobile telephones;
- portable television sets;
- portable typewriters;
- portable personal computers and accessories;
- portable calculators;
- baby carriages and strollers;
- wheelchairs for invalids; and
- sporting equipment.

(b) Duty Free Importation

The traveler shall also be allowed to import, free of import duties and taxes, the following items in reasonable quantities for personal use, excluding commercial purposes, subject to Host Country regulations but not less than:

(i) consumables: 200 cigarettes or 50 cigars or 250 grams of tobacco or an assortment of these products of a total weight not exceeding 250 grams, and 1 liter of spirits;

(ii) other goods of a noncommercial nature with an aggregate value of SDR 75.00; and

(iii) currency for living expenses: SDR 100.00 per day of stay.

The quantities and amounts may be more restricted for travelers (i) under a certain age or (ii) crossing the border frequently (more than once within 24 hours).

Article 5: Sanitary Inspection of Personal Effects

Personal effects of people crossing the border shall be subject to sanitary inspection in accordance with the provisions of Article 9 of the Agreement.

Part III: Facilitation Measures.

Article 6: Facilitation Measures

The facilitation measures shall be those stipulated in Annex 4 to the Agreement.

Part IV: Passenger Transport Conditions

Article 7: Transport Pricing

(a) For non-scheduled services, the transport price will be freely determined by market forces, but subject to antitrust restrictions, so as to avoid excessively high or low pricing. Contracting Parties and transport operators shall refrain from any measures, agreements, or practices tending to distort free and fair competition, such as cartels, abuse of dominant position, dumping, and state subsidization. They shall be denied any effect and be null and void. Contracting Parties shall ensure that their respective transport operators conform to this precept.

(b) For scheduled services, the Contracting Parties involved will agree on the transport price.

Article 8: Accompanied Luggage Allowance and Excess Luggage Charges

(a) For non-scheduled transport service the luggage allowance is left to the mutual agreement between the parties to the contract of carriage.

(b) For scheduled transport services each passenger is to be allowed to bring along free of charge luggage weighing up to 20 kilograms and of reasonable size. Transport operators may charge for excess luggage. The surcharge may vary depending on the route, but shall not exceed five percent of a full-fare passenger ticket price per excess kilogram of weight.

Article 9: Unaccompanied Luggage

The tariff for unaccompanied luggage will be governed by the regime stipulated in Annex 10 to the Agreement.

Part V: Passenger Road Carrier Liability Regime

Article 10: Scope of Application

(a) The carrier liability regime set out below shall apply to every contract for the carriage of passengers and their luggage for reward or gratuitously in the course of the carrier's business by road in a motor vehicle, when the passenger's places of departure and destination are situated in the territories of different Contracting Parties.

(b) The carrier liability for carriage of unaccompanied luggage will be governed by the regime stipulated in Annex 10 to the Agreement.

Article 11: The Contract of Carriage

(a) Transport Documents

Passenger Ticket

(i) The contract of carriage shall be recorded via the issuance of a collective or individual passenger ticket. The absence, irregularity, or loss of the ticket shall not affect the existence or the validity of the contract of carriage, which shall remain subject to the provisions of this Annex.

(ii) The ticket shall mention in the national language and in English the following particulars:

- the name and address of the carrier;
- the point of departure and destination;
- the date of the journey or the period of the validity of the ticket;
- the transport price; and
- a reference to the rule of law containing the liability regime of this Annex.

(iii) The ticket may be issued to a named person or to bearer.

Luggage Registration Voucher

(iv) For registered luggage, the carrier shall issue a luggage registration voucher, which may be combined with the passenger ticket.

(v) The luggage registration voucher shall mention in the national language and in English the following particulars:

- the name and address of the carrier;
- the point of departure and destination;
- the date of issuance;
- the transport price;
- a reference to the rule of law containing the liability regime of this Annex; and
- the number and weight of the luggage.

(vi) In case of absence of the luggage voucher or omission to indicate the weight or number of the registered luggage, the luggage weight and number shall be presumed to be the maximum allowance.

(b) Remarks

(i) Upon registration of the luggage, the carrier shall check its apparent condition, and when necessary make appropriate remarks on the luggage registration voucher.

(ii) In the absence of remarks on its condition by the carrier, the luggage is presumed to be in good condition.

Article 12: Principles of Carrier Liability

(a) Mandatory Law

Any clause in the carriage contract directly or indirectly derogating from the provisions of the carrier liability regime of this Annex, unless it is in favor of the passenger, shall be null and void. The nullity of such a stipulation shall however not affect the validity of the other provisions of the contract.

(b) In Contract and in Tort

The present liability regime will govern any claim arising out of the performance of the carriage contract under this Annex, however founded, whether in contract or extra-contractually.

(c) Vicarious Liability for Servants, Agents, and Subcontractors

In connection with his/her tasks, the carrier shall be responsible for acts and/or omissions of his/her servants, agents, and subcontractors, who will be entitled to avail themselves of the same defenses as the carrier under this Annex.

Article 13: Subject of Carrier Liability

(a) Personal Injury

The carrier shall be liable for loss or damage resulting from the death or wounding or from other bodily or mental injury caused to a passenger as a result of an accident related to the carriage and occurring while the passenger is on board or entering or exiting the vehicle.

(b) Delay

The carrier shall be liable for damages resulting from delay in the arrival of the passenger and/or his/her luggage.

(c) Loss of or Damage to Registered Luggage

(i) The carrier shall be liable for the total, or partial loss of, or damage to the luggage that occurred in the period between the time that the carrier takes the goods in charge and the time of delivery.

